
ជនជាតិខ្មែរ
ភាគ១
ស.វ.ទី១-ស.វ.ទី១៥
និពន្ធដោយ Paul Brunon
និង ស៊ុនហេង ម៉េងឈាង

# លំដាប់កាលប្រវត្តិ

## ស.វ.ទី១-ស.វ.ទី១៥ | សម័យអង្គរ




| រជ្ជកាល | ព្រះរាជា | សំណង់ធំៗ |
|---|---|---|
| ៨០២-៨៥០ | ជ័យវរ្ម័នទី២ | គូលែន |
| ៨៧៧-៨៨៩ | ឥន្ទ្រវរ្ម័នទី១ | ព្រះគោ បាគង ឥន្ទ្រតដាក |
| ៨៨៩-៩០០ | យសោវរ្ម័នទី១ | បាខែង បារាយណ៍ខាងកើត |
| ៩២៨-៩៤១ | ជ័យវរ្ម័នទី៤ | កោះកេរ្តិ៍ បារាយណ៍រ៉ាហាល់ |
| ៩៤៤-៩៦៨ | រាជេន្ទ្រវរ្ម័នទី២ | ប្រែរូប មេបុណ្យខាងកើត ផ្នែកខ្លះនៃភិមានអាកាស បន្ទាយស្រី |
| ៩៦៨-១០០១ | ជ័យវរ្ម័នទី៥ | តាកែវ (មិនទាន់ហើយ) |
| ១០០២-១០៥០ | សូរ្យវរ្ម័នទី១ | ជីសូរ ផ្នែកខ្លះនៃព្រះវិហារ បញ្ចប់ភិមានអាកាស និងតាកែវ |
| ១០៥០-១០៦៦ | ឧទយាទិត្យវរ្ម័នទី២ | បាពួន បារាយណ៍ខាងលិច មេបុណ្យខាងលិច |
| ១០៦៦-១០៨០ | ហស៌វរ្ម័នទី៣ | |
| ១០៨០-១១០៧ | ជ័យវរ្ម័នទី៦ | ភ្នំរុង ភិម៉ៃ វត្តភូ |
| | *ចលាចល* | |
| ១១១៣-១១៥០ | សូរ្យវរ្ម័នទី២ | អង្គរវត្ត បន្ទាយសំរែ ចៅសាយទេវតា ព្រះពិទូ បន្ថែមវត្តភូ ជីសូរ ព្រះវិហារ |
| ១១៥០-១១៦០ | ធរណីន្ទ្រវរ្ម័នទី២ | |
| | *ការជ្រួលច្របល់* | |
| *១១៧៧* | *ចាមវាយយកបានអង្គរ* | |
| ១១៨១-ប្រហែល១២១៨ | ជ័យវរ្ម័នទី៧ | កំពែងក្រុងអង្គរធំ បាយ័ន តាព្រហ្ម ព្រះខ័ន បន្ទាយក្តី តាសោម ក្រោលគោ នាគព័ន្ធ [illegible] តាព្រហ្ម(ទន្លេបាទី) បន្ទាយឆ្មារ |
| ប្រហែល១២១៨-១២៤៣ | ឥន្ទ្រវរ្ម័នទី២ | |
| ១២៤៣-១២៩៥ | ជ័យវរ្ម័នទី៨ | |
| ១២៩៥-១៣០៧ | ឥន្ទ្រវរ្ម័នទី៣ ស្រីន្ទ្រវរ្ម័ន | |
| ១៣០៧-១៣២៧ | ស្រីន្ទ្រជ័យវរ្ម័ន | |
| ១៣២៧-១៣៣៦ | ជ័យវរ្ម័នទី៩ | |
| ១៣៣៦-១៣៤០ | ត្រសក់ផ្អែម | |
| | *សៀមវាយយកក្រុងអង្គរ* | |
| | *អង្គរធ្លាក់ក្នុងដៃសៀម* | |
| *១៤៣១* | *ចំនាកចំនោលអង្គរ* | |

សំគាល់៖ នៅក្នុងអត្ថបទ ពាក្យដែលមានសំគាល់ដោយ សញ្ញា ▬ មានពន្យល់ន័យនៅទំព័រ៤៤។



# មាតិកា


នៅចន្លោះប្រទេសឥណ្ឌា និងប្រទេសចិន ........ 4
បុរេប្រវត្តិសាស្ត្រខ្មែរ ប្រជាជនខ្មែរ និងឥទ្ធិពលឥណ្ឌា ........ 6
អាណាចក្រភ្នំ រឺ នគរភ្នំ ស.វ.ទី១-ស.វ.ទី៦ ........ 8
អាណាចក្រចេនឡា ស.វ.ទី៦-ស.វ.ទី៨ ........ 10
សម័យអង្គរ ស.វ.ទី៩-ពាក់កណ្តាលស.វ.ទី១៥ ........ 12
ជ័យវរ្ម័នទី២-ស្តេចចក្រវាល ៨០២-៨៥០ ........ 14
ឥន្ទ្រវរ្ម័នទី១-អ្នកផ្តើមកសាងបារាយណ៍ ៨៧៧-៨៨៩ ........ 15
យសោវរ្ម័នទី១-ស្ថាបនិកទី១នៃក្រុងអង្គរ ៨៨៩-៩០០ ........ 16
រាជេន្ទ្រវរ្ម័នទី២-ការត្រលប់មកអង្គរវិញ ៩៤៤-៩៦៨ ........ 17
សូរ្យវរ្ម័នទី១-ស្តេចពុទ្ធសាសនិកទី១នៃសម័យអង្គរ ១០០២-១០៥០ ........ 18
ឧទយាទិត្យវរ្ម័នទី២ ១០៥០-១០៦៦ ហស៌វរ្ម័នទី៣ ១០៦៦-១០៨០
និងជ័យវរ្ម័នទី៦ ១០៨០-១១០៧ ........ 19
សូរ្យវរ្ម័នទី២-អ្នកកសាងប្រាសាទអង្គរវត្ត ១១១៣-១១៥០ ........ 20
ប្រាសាទអង្គរវត្ត ........ 22
ការជ្រួលច្របល់ នៅស.វ.ទី១២ និងការវាយលុករបស់ចាម ........ 24
ជ័យវរ្ម័នទី៧-មហាក្សត្រកំពូល ១១៨១-ប្រហែល១២១៨ ........ 26
ស្តេចសោយរាជ្យបន្តពីជ័យវរ្ម័នទី៧ ប្រហែល១២១៨-១៣៣៦ ........ 32
ព្រះរាជាណាចក្រជិតខាង ........ 33
ប្រតិកម្មសាសនា នៅស.វ.ទី១៣ ........ 34
ពុទ្ធសាសនាមហាយាន និងហីនយាន ........ 35
ត្រសក់ផ្អែម-ស្តេចបញ្ចប់លទ្ធិទេវរាជ ១៣៣៦-១៣៤០ ........ 36
ទំនាក់ទំនងជាមួយចិន និងសៀម នៅស.វ.ទី១៤ ........ 38
អរិយធម៌អង្គរ ........ 40
ចំនាកចំនោលក្រុងអង្គរ ........ 43
ពន្យល់ពាក្យ និងចំលើយ ........ 44

# នៅចន្លោះប្រទេសឥណ្ឌា និងប្រទេសចិន




កម្ពុជានៅចន្លោះឥណ្ឌា និងចិន។

ប្រទេសកម្ពុជាសម័យដើមមានវិសាលភាពធំធេងណាស់ ស្ថិតនៅអាស៊ីភាគអាគ្នេយ៍ ចន្លោះពិភពចាស់បុរាណពីរ គឺឥណ្ឌានៅពីខាងលិច និងចិននៅពីខាងឦសាន។

### ▶ ប្រទេសឥណ្ឌា

ឥណ្ឌាជាប្រទេសមួយធំសំបើម ស្ថិតនៅអាស៊ីភាគខាងត្បូង។ នៅជាយដែនខាងជើងប្រទេសនេះ គេឃើញមានជួរភ្នំខ្ពស់ៗហៅថាភ្នំហិមាល័យ (ខ្មែរហៅថាភ្នំហិមពាន្ត) ឯនៅជាយខាងត្បូងមានមហាសមុទ្រឥណ្ឌា។ អរិយធម៌ឥណ្ឌាជាអរិយធម៌មួយចាស់បុរាណដ៏យូរលង់ណាស់មកហើយ ដែលនៅសម័យនោះមានអក្សរសិល្ប៍សរសេរជាភាសាសំស្ក្រឹតដ៏សំបូរបែបទៅហើយ។ ជនជាតិឥណ្ឌាភាគច្រើនជាមនុស្សអំបូរអារ្យ។ ពួកគេគោរពសាសនាធំៗពីរ គឺព្រាហ្មណ៍សាសនានិងព្រះពុទ្ធសាសនា។ ពួកគេបរិភោគអាហារនិងម្រាមដៃស្តាំ។ ទន្លេគង្គា ដែលជាទន្លេមួយធំហូរចុះពីជួរភ្នំហិមាល័យរហូតដល់មហាសមុទ្រឥណ្ឌា ជាកន្លែងពិសិដ្ឋ។ ពួកហិណ្ឌូ (អ្នកកាន់ព្រាហ្មណ៍សាសនា) តែងនាំគ្នាទៅមុជទឹកលាងបាបក្នុងទន្លេនោះ។



## សាកល្បងរកចំលើយ

ប្រទេស ដែលមានប្រជាជនច្រើនជាងគេក្នុងពិភពលោកបច្ចុប្បន្ននេះ គឺ
- ▶ សហរដ្ឋអាមេរិច ?
- ▶ ប្រទេសឥណ្ឌា ?
- ▶ ប្រទេសចិន ?

ចំលើយ : ទំព័រ៤៤



មុជទឹកលាងបាបនៅក្នុងទន្លេគង្គា : ជាង២០០០ឆ្នាំមកហើយ ពួកហិណ្ឌូតែងនាំគ្នាមកមុជទឹកក្នុងទន្លេនេះ ដោយជឿជាក់ថា ទឹកនេះអាចលាងបាប និងធ្វើអោយជំងឺជាសះស្បើយ។



### ▶ ប្រទេសចិន

ចិនជាប្រទេសធំសំបើមមួយទៀត ដែលមានឋានៈជាមហាចក្រភពខ្លាំងពូកែតាំងពីសម័យបុរាណដ៏យូរលង់មកម្ល៉េះ។ គេហៅថា «ចក្រភពកណ្តាល»។ នៅជាយខាងជើងប្រទេសមានមហាកំពែង ដែលគេបានសាងសង់សំរាប់ការពារទប់ទល់និងការវាយលុកចូលពីសំនាក់ជនព្រៃផ្សៃ (ចិនប្រើពាក្យនេះហៅជនជាតិផ្សេងៗទៀត)។ ប្រទេសនេះសំបូរធ្នេរសមុទ្រ ដែលអនុគ្រោះដល់ការធ្វើជំនួញ។ ប្រទេសចិនសម័យនោះមានស្នាដៃអក្សរសិល្ប៍ដ៏សំបូរបែបនិងអ្នកកាលប្បវត្តិជាច្រើនរូប ដែលប្រើអក្សរគំនិតសំរាប់សរសេរកត់ត្រា។ ជនជាតិចិនជាមនុស្សអំបូរម៉ុងកូល។ គេប្រើចង្កឹះសំរាប់បរិភោគអាហារ ធ្វើសក្ការៈដូនតានិងមានជំនឿទៅលើទស្សនវិជ្ជាច្រើនជាងសាសនា។



មហាកំពែងប្រទេសចិន : គេបានចាប់ផ្តើមកសាងឡើងនៅ ស.វ.ទី៣ មុន គ.ស.។ វាមានប្រវែងសរុបប្រមាណ ៦៤០០ គម សង់ពីឥដ្ឋនិងថ្ម។

### ▶ ប្រទេសកម្ពុជា

កម្ពុជាស្ថិតនៅលើឧបទ្វីបឥណ្ឌូចិន ចន្លោះប្រទេសឥណ្ឌានិងចិន ដែលមានអរិយធម៌រុងរឿងដូចបានរៀបរាប់ខាងលើ។ កម្ពុជាមានទន្លេមេគង្គហូរកាត់ បឹងទន្លេសាប ទឹកដីនៅតំបន់ខាងជើង និងតំបន់ដីសណ្តទន្លេមេគង្គនៅទិសខាងត្បូង។ នៅលើទឹកដីល្អបវរសំបូរទៅដោយធនធានធម្មជាតិនេះ ប្រជាជនខ្មែរបានកកើតឡើង និងរស់នៅជាម្ចាស់ស្រុកជាប់រហូតតាំងពីបុរាណកាល ហើយក្រោយមកបានកសាងរាជាណាចក្រដ៏ធំរុងរឿងនិងជាមហាអំណាចមួយនៅអាស៊ីភាគអាគ្នេយ៍។

ក្នុងសម័យនោះដែរ នៅលោកខាងលិច ដែលស្ថិតនៅសែនឆ្ងាយ មានអរិយធម៌ធំមួយផ្សេងទៀតហៅថា អរិយធម៌មេឌីទែរ៉ានេ គឺអរិយធម៌របស់ជនជាតិក្រិចនិងជនជាតិរ៉ូម។

## वसन्तः

**ភាសាសំស្ក្រឹត**
គឺជាភាសាពិសិដ្ឋ និងភាសាអក្សរសិល្ប៍របស់ឥណ្ឌាបុរាណ។ ភាសានេះបានត្រូវជនជាតិឥណ្ឌានាំចូលមកក្នុងប្រទេសកម្ពុជា។ ជនជាតិខ្មែរបានសរសេរអត្ថបទល្អៗជាច្រើនជាភាសាសំស្ក្រឹត ដែលគេបានប្រើជាភាសាផ្លូវការរស់កាលយូរ។




**អក្សរចិន**
ជនជាតិចិនប្រើអក្សរគំនិត ដែលមិនមែនជាតួអក្សរទេ តែជាគំនូរ។ គេសរសេរនឹងជក់ ហើយអានតាមបន្ទាត់ឈរពីលើចុះក្រោម និងពីស្តាំមកឆ្វេង។

# បុរេប្រវត្តិសាស្ត្រខ្មែរ ប្រជាជនខ្មែរ និងឥទ្ធិពលឥណ្ឌា



កុលាលភាជន៍នៃស.វ.ទី៣មុន គ.ស. ដែលគេកាយបាននៅភូមិបន្ទាត់បោះ ក្នុងខេត្តបន្ទាយមានជ័យ។

**អ្នកឯកទេសបានធ្វើការសិក្សាស្រាវជ្រាវនិងបញ្ជាក់ថា ទឹកដីខ្មែរមានមនុស្សរស់នៅតាំងពីសម័យដ៏សែនយូរលង់ណាស់មកម្ល៉េះ។**

## ▶ បុរេប្រវត្តិសាស្ត្រខ្មែរ

កាលសម័យដ៏វែងចាប់ពីពេលមានមនុស្សរស់នៅ រហូតដល់ពេលមនុស្សចេះប្រើអក្សរសំរាប់កត់ត្រា មានឈ្មោះហៅថា «បុរេប្រវត្តិសាស្ត្រ»។ កាលសម័យបន្ទាប់មក ហៅថា «ប្រវត្តិសាស្ត្រ»។ ចំពោះបុរេប្រវត្តិ-សាស្ត្រខ្មែរ គេយល់ដឹងបានតិចតួចណាស់។ ការសិក្សាពីស្ថានីយបុរេ-ប្រវត្តិផ្សេងៗដូចជា ស្ថានីយល្អាងស្ពាន (ខេត្តបាត់ដំបង) សំរោងសែន និងអន្លង់ផ្ដៅ (ខេត្តកំពង់ឆ្នាំង) ម្លូព្រៃ (ខេត្តព្រះវិហារ) ព្រែកឆ្លង (ខេត្តក្រចេះ) និងក្បាលរមាស (ខេត្តកំពត) បានអោយគេយល់ដឹងខ្លះៗពីការរស់នៅរបស់ដូនតាយើង។ ស្ថានីយល្អាងស្ពានបានអោយដឹងថា នៅតំបន់នោះមានមនុស្សរស់នៅតាំងពីជាង៤០០០ឆ្នាំមុនគ.ស.ម្ល៉េះ (ស្រទាប់ទី៤)។ ពួកគេចេះធ្វើកុលាលភាជន៍ សំរាប់ប្រើប្រាស់ហើយ។

## ▶ ប្រជាជនខ្មែរ

ខ្មែរជាជនជាតិមានចំនាស់ ដែលបានរស់នៅជាអ្នកស្រុកដើមក្នុងតំបន់អាស៊ីភាគអាគ្នេយ៍ ជាយូរលង់ណាស់មកហើយ តាំងពីមុនឥណ្ឌានិងចិនចូលមកម្ល៉េះ។ ខ្មែរស្ថិតក្នុងអំបូរអូស្ត្រូអាស៊ី រឺអាស៊ីខាងត្បូង។ ភាសាខ្មែរស្ថិតក្នុងអំបូរភាសាខ្មែរ-មន ដែលមានភាសាជាច្រើនទៀត នៅអាស៊ីភាគអាគ្នេយ៍។ តាំងពីព្រេងនាយមក ជនជាតិខ្មែរបានទទួលពីបុព្វបុរសរបស់ខ្លួននូវជំនឿដូនតានិងទំនៀមទំលាប់ដូចជា ការគោរពសត្វនាគ ជំនឿលើខ្មោចព្រាយ អ្នកដូនអ្នកតា-ល-។ ក្រោយមកពួកគេបានទទួលឥទ្ធិពលពីបរទេសដូចជា ឥណ្ឌា ចិន ថ្វា ជាដើម។

### សំណាញ់និងមេថា

ដើម្បីដឹងថាឆ្នាំណាមួយស្ថិតនៅក្នុងសតវត្សណា យើងត្រូវយកលេខចំនួនរយ + ១

ឧទាហរណ៍ :

៧៥ - ០៧៥ - ស.វ.ទី១ (០+១)

៨០២ - ស.វ.ទី៩ (៨+១)

១៩៥៣ - ស.វ.ទី២០ (១៩+១)

២០០៣ - ស.វ.ទី២១ (២០+១)

ប៉ុន្តែចំពោះឆ្នាំ ដែលមានលេខ ០០ នៅខាងចុង គេត្រូវគិតបែបផ្សេង ឧទាហរណ៍ :

៨០០ - ឆ្នាំចុងក្រោយបំផុតនៃស.វ.ទី៨។



## ▶ ឥទ្ធិពលឥណ្ឌា

ប្រជាជនខ្មែរបានទទួលឥទ្ធិពលមួយផ្នែកធំពីអរិយធម៌ឥណ្ឌា។ គេបានដឹងច្បាស់ថា តាំងពីយូរលង់មកហើយ ពួកឥណ្ឌាបានចូលមកកាន់ឆ្នេរសមុទ្រខ្មែរនិងកោះធំៗនៅអាស៊ីភាគអាគ្នេយ៍ដើម្បីធ្វើជំនួញ។ ប៉ុន្តែឥទ្ធិពលឥណ្ឌាបានចូលជ្រួតជ្រាបយ៉ាងជ្រៅទៅក្នុងស្រទាប់ប្រជាជនតាមបែបសន្តិវិធី ពោលគឺប្រជាជនក្នុងភូមិភាគនេះស្ម័គ្រចិត្តទទួលយកប្រពៃណីឥណ្ឌា បន្តិចម្តងៗដោយគ្មានការបង្ខិតបង្ខំឡើយ។ ការផ្សព្វផ្សាយឥទ្ធិពលឥណ្ឌានេះ ដែលគេហៅថាឥណ្ឌាកម្ម បានប្រព្រឹត្តទៅអស់រយៈពេលជាច្រើនសតវត្ស ៖ ឥណ្ឌាបាននាំអក្សរសិល្ប៍ សិល្បៈ របៀបគ្រប់គ្រងសង្គម របៀបរស់នៅ ព្រាហ្មណ៍សាសនា និងព្រះពុទ្ធសាសនាមកអោយប្រជាជន។ ដោយហេតុនោះ បន្តិចម្តងៗសង្គមខ្មែរយើងបានជ្រួតជ្រាបដោយគំនិត និងជំនឿនៃប្រពៃណីឥណ្ឌា។



១



២

**វីរកថាឥណ្ឌាធំៗ ដែលខ្មែរនិយម មាន២ ៖**

- រាមាយណៈ (រូប១) និទានពីក្សត្រមួយអង្គឈ្មោះព្រះរាម ដែលជាអវតាររបស់ព្រះវិស្ណុ។ ព្រះអង្គមានស្តេចស្វា ឈ្មោះហនុមានជាសេនា ហើយប្រយុទ្ធតទល់នឹងស្តេចយក្សឈ្មោះក្រុងរាពណ៍។ វីរកថាខ្មែរមានឈ្មោះថារាមកេរ្តិ៍។
- មហាភារតៈ (រូប២) និទានពីអវតារមួយអង្គរបស់ព្រះវិស្ណុឈ្មោះក្រឹស្ណៈ។

### ព្រាហ្មណ៍សាសនា រឺ សាសនាព្រាហ្មណ៍

មានអាទិទេពធំៗបីអង្គគឺ ព្រះព្រហ្ម ព្រះសិវៈ និងព្រះវិស្ណុ។ ប្រជាជនខ្មែរយើងច្រើនតែគោរពបូជាចំពោះព្រះសិវៈ និងព្រះវិស្ណុ។



### ព្រះសិវៈ រឺ ព្រះឥស្វរ

ជាអាទិទេពបង្កើតលោកនិងបំផ្លាញលោក។ ព្រះសិវៈមានដៃច្រើន ហើយមានគោនន្ទិនជាជំនិះ។

### ព្រះវិស្ណុ រឺព្រះនារាយណ៍



ជាអាទិទេពរក្សាលោក។ ព្រះវិស្ណុបានយកកំណើតជួនកាលជាសត្វ ជួនកាលជាមនុស្ស ដើម្បីជួយស្រោចស្រង់សត្វលោក។ ព្រះអង្គមានដៃច្រើន ហើយមានសត្វគ្រុឌជាជំនិះ។

# អាណាចក្រភ្នំ រឺ នគរភ្នំ

## ស.វ.ទី១-ស.វ.ទី៦



នៅដើមគ្រិស្តសករាជ បុព្វបុរសខ្មែរបានបង្កើតរដ្ឋមួយ ដែលលាតសន្ធឹងនៅលើឧបទ្វីបឥណ្ឌូ-ចិន។ រដ្ឋនោះមានឈ្មោះថា អាណាចក្រភ្នំ រឺនគរភ្នំ (ចិនហៅថាហ្វូណន)។

### ▶ នគរភ្នំ ជារដ្ឋខ្មែរដំបូង

ពត៌មានស្តីពីអាណាចក្រភ្នំ រឺនគរភ្នំ និងពីគ្រាដំបូងនៃប្រវត្តិសាស្ត្រខ្មែរ ភាគច្រើនមានប្រភពដើមមកពីឯកសារចិន។ ឯកសារទាំងនោះទាក់ទងទៅនឹងបេសកកម្មរបស់អ្នកដំនើរជាតិចិន២នាក់ ដែលបានមកកាន់អាណាចក្រភ្នំនៅពាក់កណ្តាលស.វ.ទី៣នៃគ.ស.។ អ្នកដំនើរម្នាក់ក្នុងចំនោមអ្នកទាំងពីរបានកត់ត្រារឿងព្រេងស្តីពីដើមកំនើតនគរភ្នំដូចតទៅ។ មានព្រាហ្មណ៍ជាតិឥណ្ឌាម្នាក់ឈ្មោះហ៊ុនទៀន (កៅណ្ឌិន្យ) បានជិះសំពៅធ្វើដំនើរតាមសមុទ្រមកដល់ឆ្នេរនគរមួយ។ រាជិនីនគរនោះមានឈ្មោះថានាងលីវយី (សោមា) ដែលជាបុត្រីរបស់ស្តេចភុជង្គនាគ បានលើកទ័ពមកបំរុងនឹងដណ្តើមយកសំពៅនោះ តែត្រូវហ៊ុនទៀនយកធ្នូទិព្វបាញ់ធ្វើអោយសំពៅព្រះនាងធ្លាយ។ ព្រះនាងភិតភ័យជាខ្លាំង ហើយព្រមទទួលយកហ៊ុនទៀនជាស្វាមី។ ហ៊ុនទៀនក៏បានឡើងសោយរាជសម្បត្តិ ហើយបង្កើតរាជវង្សមួយនៅនគរនោះទៅ។

ចំនែកឯអ្នកប្រវត្តិសាស្ត្រ ដោយផ្អែកលើឯកសារសរសេរ ប្រាង្គប្រាសាទ សិលាចារឹកនិងវត្ថុទាំងឡាយបានមកពីកំនាយនានា បានបញ្ជាក់ថា នាដើមគ្រិស្តសករាជ មានរដ្ឋខ្មែរមួយបានកើតឡើងនៅលើឧបទ្វីបឥណ្ឌូចិន។ រដ្ឋនោះ (ចិនហៅថាហ្វូណន) មានព្រំដែនខាងត្បូងជាប់សមុទ្រ ហើយមានអត្ថិភាពនៅរហូតដល់ស.វ.ទី៦។

ល្អាងមួយក្នុងចំនោមល្អាងទាំង ៨ នៅចង្កេះភ្នំដា ក្នុងស្រុកអង្គរបុរី ខេត្តតាកែវ។ គេបានចោះល្អាងទាំងនេះ សំរាប់ធ្វើជាកន្លែងសក្ការៈ។

### ? សាកល្បង រកចំលើយ

នគរភ្នំ រឺអាណាចក្រភ្នំ (ចិនហៅថាហ្វូណន) មានឈ្មោះដូចនេះ ពីព្រោះរដ្ឋនេះ
- ▶ ស្ថិតនៅលើភ្នំ ?
- ▶ មានភ្នំច្រើន ?
- ▶ មានស្តេចសោយរាជ្យដែលមានងារជា «ស្តេចភ្នំ» ?

ចំលើយ : ទំព័រ៨៨

នៅសម័យនោះ នៅលោកខាងលិច ចក្រភពរ៉ូមកំពុងមានអំនាចខ្លាំងពូកែ។



### ▶ អរិយធម៌អ្នកស្រុកនគរភ្នំ



ព្រះពុទ្ធរូបសម័យនគរភ្នំ

គេដឹងថា នគរភ្នំជារដ្ឋធ្វើជំនួញតាមសមុទ្រជាមួយប្រទេសចិន ចាម្ប៉ា ឥណ្ឌា និងប្រទេសនៅទ្វីបអឺរ៉ុបដូចជាចក្រភពរ៉ូមជាដើម។ កំនាយនៅស្ថានីយបុរេប្រវត្តិអូរកែវក្នុងដីសណ្តទន្លេមេគង្គ បានបង្ហាញអោយឃើញថា ទីក្រុងនេះជាកំពង់ផែដ៏ធំមួយ ដែលមានលក់ដូរលោហធាតុ មានតំលៃ ភ្លុក គជ់ ឈើ-ល-។ នៅសម័យរុងរឿងដល់កំពូល នគរភ្នំត្រួតត្រាលើក្រុងព្រះរីតូចៗជាច្រើនតាំងនៅតាមឆ្នេរសមុទ្រ ដែលសុទ្ធតែទទួលឥទ្ធិពលពីឥណ្ឌាដែរ។ ប្រវត្តិសាស្ត្រអាណាចក្រភ្នំនៅមានលក្ខណៈមិនសូវច្បាស់លាស់ពីព្រោះយើងមានពត៌មានតិចតួចពេកពីសម័យនោះ។ ប៉ុន្តែគេដឹងច្បាស់ថាមានស្តេចច្រើនអង្គបានឡើងសោយរាជ្យជាបន្តបន្ទាប់ ហើយស្តេចចុងក្រោយបង្អស់មាននាមថា រុទ្រវរ្ម័ន (៥១៤-៥៥០)។ អ្នកនគរភ្នំគោរពបូជាចំពោះសាសនាធំៗចំនួន២ : ព្រាហ្មណ៍សាសនា និងព្រះពុទ្ធសាសនា។ គេសរសេរជាភាសាសំស្ក្រឹត ដែលមានប្រភពដើមមកពីឥណ្ឌា។ អ្នកស្រុកស្លៀកសំពត់ចងក្បិន និងលែងដងខ្លួនទទេ។ គេរស់នៅក្នុងផ្ទះសង់អំពីឈើ ខ្ពស់ផុតពីដី។ ពួកគេជាសិប្បករយ៉ាងចំនាន។ ពួកគេចេះធ្វើប្រព័ន្ធប្រលាយបង្ហូរទឹកស្រោចស្រពស្រែនិងចេះធ្វើសំពៅធំៗសំរាប់ធ្វើជំនួញ រឺធ្វើសង្គ្រាម។ សព្វថ្ងៃនេះ អ្នកប្រវត្តិសាស្ត្រខ្លះគិតថា អង្គរបុរីក្នុងខេត្តតាកែវជារាជធានីដំបូងរបស់នគរភ្នំ។



#### ជំនួញនៅតាមឆ្នេរសមុទ្រនគរភ្នំ

នៅស្ថានីយអូរកែវ (សព្វថ្ងៃនៅក្នុងប្រទេសវៀតណាម) ដែលជាទីក្រុង និងជាកំពង់ផែមួយយ៉ាងធំរបស់នគរភ្នំ គេបានរកឃើញគ្រឿងអលង្ការជាច្រើន កាសប្រាក់ ដែលមានខ្លះមកពីចក្រភពរ៉ូម ព្រះពុទ្ធរូបតូចៗប្រដាប់ប្រដាប្រើប្រាស់...។

#### អត្ថបទនេះមានប្រភពដើមពីចិន

« អ្នកស្រុកនគរភ្នំធ្វើចិញ្ចៀននិងខ្សែដៃពីមាស និងចានក្បានពីប្រាក់។ គេកាប់ដើមឈើយកមកធ្វើផ្ទះ។ ព្រះរាជាគង់នៅក្នុងព្រះពន្លាខ្ពស់មានពីរជាន់។ អ្នកស្រុកយកឈើធ្វើរបងផ្ទះ។ នៅមាត់សមុទ្រ មានដុះដើមឫស្សី (ដើមចាក ?)... គេយកស្លឹកវាមកដេរប្រក់ផ្ទះ។ ប្រជាជនរស់នៅលើផ្ទះសង់ខ្ពស់ផុតពីដី។ »



**សិលាចារឹកខ្មែរ**

សិលាចារឹកជាភាសាខ្មែរដំបូង គឺសិលាចារឹកអង្គរបុរី ដែលមានចុះកាលបរិច្ឆេទឆ្នាំ៦១១ ក្រោយគ.ស.។

# អាណាចក្រចេនឡា

## ស.វ.ទី៦–ស.វ.ទី៨

**នៅខាងលើនគរភ្នំ ខ្មែរភាគខាងជើងក៏បានបង្កើតជារដ្ឋមួយដែរឈ្មោះថា ចេនឡា។ ក្រោយមក រដ្ឋចេនឡាលើកទ័ពមកវាយយកបាននគរភ្នំ ហើយនៅស.វ.ទី៧ បានបង្រួបបង្រួមទឹកដីនគរទាំងពីរ។**

### ▶ ចេនឡា ជាចក្រភពខ្មែរបុរេអង្គរ

ឯកសារចិនបានឈប់លែងនិយាយពីនគរភ្នំនាចុងស.វ.ទី៦។ ប៉ុន្តែពួកអ្នកប្រវត្តិសាស្ត្រគិតថា ក្នុងពេលរដ្ឋនគរភ្នំធ្លាក់ចុះខ្សោយខាងផ្នែកជំនួញនិងផ្នែកនយោបាយ ក្សត្របុរីតូចៗ ដែលស្ថិតនៅប៉ែកខាងជើងឆ្ងាយពីមាត់សមុទ្រ បានពង្រីងអំនាចរបស់ខ្លួនខ្លាំងឡើងៗ។ ក្នុងចំនោមក្សត្របុរីទាំងនោះ ដែលជាសាមន្តរដ្ឋរបស់នគរភ្នំ មានក្សត្របុរីមួយឈ្មោះចេនឡា (ហៅតាមចិន)។ ចេនឡាស្ថិតនៅភាគខាងជើង (ក្នុងភាគខាងត្បូងប្រទេសឡាវសព្វថ្ងៃ) និងមានរាជធានីឈ្មោះភវបុរៈ។ ស្តេចរបស់រដ្ឋនេះ ព្រះនាមភវវរ្ម័នទី១ (៥៥០–៦០០) និងស្តេចសោយរាជ្យបន្ទាប់មកទៀត មហេន្ទ្រវរ្ម័នទី១ (៦០០–៦១៥) និងឥសានវរ្ម័នទី១ (៦១៦–៦៣៥) បានធ្វើសង្គ្រាមវាយយកទឹកដីនគរភ្នំរហូតបានទាំងស្រុង ហើយប្រសិទ្ធនាមថា «ចេនឡាធំ» (ចេនឡា និងនគរភ្នំ)។ គេបានរកឃើញសិលាចារឹកសរសេរជាភាសាសំស្ក្រឹត និងភាសាខ្មែរ ដែលនិយាយពីសម័យនោះ។ ក្រោយមក ប្រទេសចេនឡាធំបានចុះទន់ខ្សោយ ហើយធ្លាក់ទៅក្នុងភាពច្របូកច្របល់ និងការបែកបាក់ផ្ទៃក្នុង។ ក្សត្របុរីជាសាមន្តរដ្ឋនានាក៏បានងើបឡើងច្បាំងគ្នាដណ្តើមអំនាចរៀងខ្លួន។ ឯកសារចិនបានបញ្ជាក់ថា នៅដើមស.វ.ទី៨ ចេនឡាធំត្រូវបែងចែកជា២ : ចេនឡាដីគោកនៅខាងជើង លើទឹកដីចេនឡាមុន (រាជធានីនៅភវបុរៈ) និងចេនឡាទឹកលិចនៅខាងត្បូង មានរាជធានីនៅសម្ភុបុរៈ (ក្នុងស្រុកសំបូរ ខេត្តក្រចេះសព្វថ្ងៃ)។ នៅទីបំផុត ចេនឡាទឹកលិចក៏បែកជា៥ទៀត រួចធ្លាក់ទៅក្រោមអំនាចត្រួតត្រារបស់ជ្វា (ឥណ្ឌូនេស៊ីសព្វថ្ងៃ) អស់រយៈពេលប្រមាណមួយទសវត្សនាចុងសតវត្សទី៨។




**ផែនទីតំបន់នៅរវាងស.វ.ទី៦–៨**

នៅសម័យនោះ ប្រទេសកម្ពុជាមានអ្នកជិតខាងដូចជា :

- ▶ នៅខាងកើត មានជនជាតិចាម ដែលបានបង្កើតរដ្ឋមួយហៅថាចាម្ប៉ា។ ចាម្ប៉ាទទួលឥទ្ធិពលឥណ្ឌាដែរ។
- ▶ នៅខាងជើងចាម្ប៉ា មានជនជាតិយួន។ យួនទទួលឥទ្ធិពលពីចិន។
- ▶ នៅខាងជើងប្រទេសខ្មែរ មានជនអំបូរថៃ ដែលរស់នៅក្នុងភាគខាងត្បូងនៃប្រទេសចិន។ នៅស.វ.ទី៨ ពួកគេចាប់ផ្តើមធ្វើដំណើរចុះមកភាគខាងត្បូង។
- ▶ នៅខាងលិចប្រទេសខ្មែរ ជនជាតិមនរស់នៅក្នុងជ្រលងទន្លេមេណាម។

········ ព្រំដែនអាណាចក្រចេនឡា
········ ព្រំដែនបច្ចុប្បន្ន



ប្រាសាទមួយក្នុងបណ្តាប្រាសាទធ្វើពីឥដ្ឋ និងសង់ឡើងជាក្រុមនៅឥសានបុរៈ រឺសំបូរព្រៃគុក។

### ▶ អរិយធម៌ខ្មែរសម័យចេនឡា

ឯកសារចិនបានសរសេរពីសម័យចេនឡាថា ក្នុងរជ្ជកាលព្រះបាទឥសានវរ្ម័នទី១ រាជធានីមានឈ្មោះថា ឥសានបុរៈ (សំបូរព្រៃគុកខាងជើងក្រុងកំពង់ធំ) ហើយមានមនុស្សរស់នៅជាង២០០០០គ្រួសារ។ ទីក្រុងតូចៗមានចំនួន៣៣។ ក្រុងនីមួយៗមានមនុស្សច្រើនពាន់គ្រួសារ និងមានមន្ត្រីម្នាក់ជាអ្នកគ្រប់គ្រង។ បីថ្ងៃម្តង ព្រះរាជាបើកសវនាការនៅក្នុងបន្ទប់ធំមួយនៅកណ្តាលទីក្រុង។ អ្នកស្រុកចេនឡាមានមាឌតូច។ ទាំងប្រុសទាំងស្រីបួងសក់ ហើយពាក់រយ៉ា។ រាល់ព្រឹក គេលុបលាងខ្លួនហើយសូត្រធម៌។ ចំពោះអាហារ គេចូលចិត្តហូបបាយ សាច់ ទឹកដោះ និងស្ករ។ គេគោរពសាសនាធំៗពីរ គឺសាសនាព្រាហ្មណ៍និងសាសនាព្រះពុទ្ធ។ គេកសាងប្រាសាទអំពីឥដ្ឋ។



**ហរិហរៈប្រាសាទអណ្តែត (ស.វ.ទី៧)**

ហរិហរៈ ជាអាទិទេពផ្សំចំរុះ :

- ▶ ខាងស្តាំជាព្រះសិវៈ
- ▶ ខាងឆ្វេងជាព្រះវិស្ណុ។

ក្នុងសម័យនោះ នៅបស្ចិមប្រទេស ចក្រភពរ៉ូមបានត្រូវបំផ្លិចបំផ្លាញដោយជនព្រៃផ្សៃ។

# សម័យអង្គរ

## ស.វ.ទី៩–ពាក់កណ្ដាលស.វ.ទី១៥

សម័យអង្គរចាប់ផ្ដើមពីគ.ស. ៨០២ (ឆ្នាំដែលព្រះបាទជ័យវរ្ម័នទី២ធ្វើពិធីទេវរាជនៅលើភ្នំគូលែន) ហើយចប់នៅគ.ស.១៤៣១ (ឆ្នាំដែលព្រះបាទពញាយ៉ាតចាកចោលអង្គរ)។

សម័យកាលនេះជាសម័យរុងរឿងបំផុតនៃប្រវត្តិសាស្ត្រខ្មែរ ដែលមានទីក្រុងអង្គរជាភស្តុតាង។ មានស្ដេចច្រើនអង្គបានឡើងសោយរាជ្យជាបន្តបន្ទាប់ក្នុងរយៈកាលជាង៦០០ឆ្នាំនៃសម័យដ៏ថ្កើងនេះ ដែលពេលខ្លះត្រូវអាប់អួដោយការចូលលុកពីជនបរទេសផងដែរ។ ព្រះរាជាមួយចំនួនជាព្រះរាជាមានអំនាចខ្លាំងពូកែ ល្បីល្បាញខាងការពារនិងកសាងជាតិ។ ព្រះអង្គបានបន្សល់ទុកអោយកូនចៅជំនាន់ក្រោយនូវបេតិកភណ្ឌសំបូរបែប ដូចជាប្រាង្គប្រាសាទជាច្រើន (ខ្លះសង់ពីឥដ្ឋ ខ្លះទៀតពីថ្មបាយក្រៀមនិងថ្មភក់) និងអាងទឹកធំៗហៅថាបារាយណ៍ដើម្បីស្តុកទឹកសំរាប់ប្រើប្រាស់ក្នុងកសិកម្មនិងគ្រួសារ ព្រមទាំងផ្លូវស្ពានធំៗ ដែលមានខ្លះយើងនៅប្រើសព្វថ្ងៃនៅឡើយដូចជា «ស្ពានប្រាប់ទិស» នៅកំពង់ក្ដីតាមផ្លូវជាតិលេខ៦ និង «ស្ពានទ័ព» ស្ថិតនៅជិតអូរជីកតាមផ្លូវទៅខេត្តឧត្ដរមានជ័យ។ នៅសម័យអង្គរ កម្ពុជាជាចក្រភពមួយមានផ្ទៃដីធំធេងណាស់ លាតសន្ធឹងនៅលើទឹកដីថៃបច្ចុប្បន្ន និងពីភាគខាងត្បូងប្រទេសឡាវរហូតដល់សមុទ្រ។ ប៉ុន្តែចាប់ពីពាក់កណ្ដាលស.វ.ទី១៣មក ដោយសារមូលហេតុផ្សេងៗ ប្រទេសកម្ពុជាបានចុះខ្សោយ។ ឯពួកសៀម ដែលបានធ្វើដំណើរចេញមកពីតំបន់ខាងត្បូងរបស់ប្រទេសចិន (ពីរាជាណាចក្រណាន់ចៅ ក្នុងតំបន់យូណាន) បានចុះមកខាងត្បូងមករស់នៅលាយឡំជាមួយខ្មែររហូតបង្កើតបានជារដ្ឋ រួចធ្វើចំបាំងវាតទីមកលើទឹកដីខ្មែរជាបន្តបន្ទាប់។ ក្រោយពីកងទ័ពសៀមវាយលុកចូល ហើយដណ្ដើមយកបានក្រុងអង្គរ ព្រមទាំងឆក់ប្លន់ទ្រព្យសម្បត្តិ កាប់សំលាប់និងកៀរប្រជារាស្ត្រនាំយកទៅជាឈ្លើយអស់ជាច្រើនមក ព្រះបាទពញាយ៉ាតក៏សំរេចចិត្តចាកចោលអង្គរ។ ក្នុងឆ្នាំ១៤៣១ ព្រះអង្គបានលើករាជធានីពីអង្គរមកតាំងនៅទួលបាសាន (ស្រីសន្ធរ ខេត្តកំពង់ចាម) រួចបន្ទាប់មកនៅចតុមុខក្នុងឆ្នាំ១៤៣២។ ចាប់ពីពេលនោះមក ប្រវត្តិសាស្ត្រខ្មែរចូលទៅក្នុងសម័យមួយថ្មីទៀតគឺ សម័យចតុមុខ។

### សំណង់ដ៏រឹងមាំ

សំណង់ធ្វើពីថ្មមានតែប្រាង្គប្រាសាទប៉ុណ្ណោះ ឯសំណង់ផ្សេងៗទៀតសុទ្ធតែសង់ពីសំភារៈឆាប់ពុករលួយ ដូចជាឈើ ឫស្សី ស្បូវ...។



«ស្ពានប្រាប់ទិស» នៅកំពង់ក្ដីសង់ដោយព្រះបាទជ័យវរ្ម័នទី៧ មានបណ្ដោយ៨០ម អាយុជិត ១០០០ឆ្នាំហើយ។

### ជាបេតិកភណ្ឌពិភពលោក

រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរដែលបច្ចុប្បន្នត្រូវគំនត់លើផ្ទៃដី ៤០២ គម² មានប្រាសាទរាប់រយប្លែកៗគ្នា ទាំងទំហំ ទាំងរចនាបថ។ នៅឆ្នាំ១៩៩២ រមណីយដ្ឋានអង្គរ បានទទួលចំនាត់ថ្នាក់ជាបេតិកភណ្ឌពិភពលោករបស់មនុស្សជាតិពីអង្គការយូណេស្កូ។



# ជ័យវរ្ម័នទី២–ស្តេចចក្រវាល

៨០២–៨៥០



## សាកល្បងរកចម្លើយ

និមិត្តរូបសំខាន់នៃទេវរាជ គឺសិវលិង្គ ដែលជាតំណាង :

- ▶ ព្រះឥសូរ ?
- ▶ ព្រះរាជា ?
- ▶ ភ្នំព្រះសុមេរុ ?

ចំលើយ : ទំព័រ៤៤

## សិលាចារឹក

« ព្រះអង្គយាងមកពីកោះជ្វា ដើម្បីសោយរាជ្យក្នុងក្រុងឥន្ទ្របុរៈ ដែលជាក្រុងសំរាប់បុត្រព្រះឥន្ទ្រ... ដើម្បីវិបុលភាពរបស់ប្រជារាស្ត្រ ក្នុងពូជព្រះរាជាដ៏សែនបរិសុទ្ធនេះ ដូចមហាឈូក ដែលបានចាក់ឫសទៅហើយ ទ្រង់លេចចេញមកដូចពន្លកថ្មី...។ »

**នៅចុងស.វ.ទី៨ ដោយសារការបែកបាក់គ្នាផង និងស្ថិតនៅក្រោមអំនាចជនជាតិជ្វាផង ប្រទេសខ្មែរបានធ្លាក់ចុះទន់ខ្សោយ និងស្ថិតនៅក្នុងសភាពអាប់អួខ្លាំង។ អ្នករំដោះ និងបង្រួបបង្រួមជាតិឡើងវិញ គឺព្រះបាទជ័យវរ្ម័នទី២។**

ប្រហែលនៅឆ្នាំ៨០០ ក្សត្រខ្មែរមួយអង្គ ដែលប្រហែលជាពួកជ្វាបានកៀរយកទៅជាឈ្លើយសឹកនោះ បានយាងត្រលប់ពីកោះជ្វាមកវិញ។ ព្រះអង្គចាប់ផ្ដើមបង្រួបបង្រួមជាតិ រួចបានឡើងសោយរាជ្យដោយមានព្រះនាមថាព្រះបាទជ័យវរ្ម័នទី២។ រជ្ជកាលរបស់ព្រះអង្គជាការចាប់ផ្ដើមនៃសម័យអង្គរ។ ប៉ុន្តែមុននឹងឡើងសោយរាជ្យ ព្រះអង្គយាងទៅគង់នៅក្នុងតំបន់ផ្សេងៗជាច្រើន ដើម្បីស្វែងរកការគាំទ្រពង្រឹងអំនាច។ ចុងក្រោយព្រះអង្គយាងទៅគង់លើភ្នំគូលែន។ សិលាចារឹកស្ដុកកក់ធំ (ស.វ.ទី១១) ប្រាប់អោយដឹងថា នៅលើភ្នំគូលែន ក្នុងឆ្នាំ៨០២ ព្រះបាទជ័យវរ្ម័នទី២បានប្រារព្ធធ្វើពិធីទេវរាជ ដែលរំដោះស្រុកខ្មែរអោយរួចពីចំនុះជ្វា ធ្វើអោយព្រះអង្គមានឋានៈជាអាទិទេព និងជាស្តេចចក្រវាល ដែលមានអំនាចគ្រប់គ្រងទៅលើសព្វសត្វ។ នៅលើភ្នំគូលែន ព្រះអង្គបានសាងប្រាសាទភ្នំមួយយ៉ាងធំ (ព្រះអារាមរោងចិន) ដែលធ្វើអោយភ្នំនេះមានល្បោះល្បី។ បន្ទាប់មក ព្រះអង្គយាងចុះពីភ្នំគូលែនទៅតាំងរាជធានីនៅហរិហរាល័យ (រលួសសព្វថ្ងៃ) ខាងកើតក្រុងអង្គរវិញ។ ព្រះអង្គគង់នៅក្រុងនោះរហូតដល់ចូលទិវង្គតនៅឆ្នាំ៨៥០។

### ប្រាសាទភ្នំ

ប្រាសាទភ្នំជាប្រាសាទសង់ឡើងសំរាប់តំកល់សិវលិង្គ គឺលិង្គព្រះឥសូរ។ គេច្រើនសង់ប្រាសាទភ្នំនៅលើភ្នំ រឺលើទីខ្ពស់។ បើសង់លើដីរាបវិញ ប្រាសាទនោះត្រូវមានថ្នៀនច្រើនជាន់ដើម្បីតំណាងភ្នំ ព្រោះគេជឿថា ព្រះឥសូរ រឺព្រះសិវៈគង់នៅលើភ្នំកៃលាសក្នុងជួរភ្នំហិមាល័យ។



# ឥន្ទ្រវរ្ម័នទី១–អ្នកផ្ដើមកសាងបារាយណ៍

៨៧៧–៨៨៩



ប្រាសាទព្រះគោសង់ពីឥដ្ឋ មានប្រាង្គ៦ តំរៀបជា២ជួរមុខក្រោយ សាងសង់ក្នុងរាជ្យព្រះបាទឥន្ទ្រវរ្ម័នទី១។

**នៅឆ្នាំ៨៧៧ ព្រះបាទឥន្ទ្រវរ្ម័នទី១ បានឡើងសោយរាជសម្បត្តិ។ ភ្លាមៗនោះ ព្រះអង្គចាប់ផ្ដើមការងារកសាងសំនង់ធំៗជាបន្តបន្ទាប់។**

នៅពេលព្រះបាទជ័យវរ្ម័នទី២សោយទិវង្គតទៅ បុត្រារបស់ព្រះអង្គព្រះនាមជ័យវរ្ម័នទី៣បានឡើងសោយរាជ្យស្នងហើយបន្តគង់នៅរាជធានីហរិហរាល័យរហូតដល់ឆ្នាំ៨៧៧។ នៅឆ្នាំនោះ ព្រះបាទឥន្ទ្រវរ្ម័នទី១បានទទួលរាជសម្បត្តិបន្ត។ ក្សត្រអង្គនេះជាព្រះរាជាទី១ដែលបានអនុវត្តកម្មវិធីការងារកសាងសំនង់ធំៗ។ ក្នុងរាជ្យព្រះអង្គ ទ្រង់បានសាងបារាយណ៍លលៃ (ឥន្ទ្រតដាក) សំរាប់ផ្គត់ផ្គង់ទឹកដល់រាជធានីផង និងយកទឹកស្រោចស្រពស្រែផង។ ប្រជាជនខ្មែរមានប្រព័ន្ធប្រឡាយទឹកសំរាប់ផ្គត់ផ្គង់ដល់កសិកម្ម ដែលធ្វើអោយប្រទេសសំបូររុងរឿង និងខ្លាំងពូកែ។ ទ្រង់បានកសាងប្រាសាទព្រះគោសង់ពីឥដ្ឋដើម្បីឧទ្ទិសចំពោះបុព្វបុរស និងប្រាសាទបាគងដែលជាប្រាសាទភ្នំសង់អំពីថ្មភក់លើថ្នៀន៥ជាន់សំរាប់តំកល់លិង្គព្រះឥសូរ។ នេះជាលើកទីមួយហើយ ដែលគេបានប្រើថ្មច្រើនក្នុងការសាងសង់ប្រាង្គប្រាសាទ។ ព្រះអង្គជាអ្នកបង្កើតរចនាបថមួយនៃសិល្បៈខ្មែរ គឺរចនាបថព្រះគោ។

## សំណាញ់ដឹងទេថា

នៅក្បាលស្ពាន ដែលពួកបរទេសច្រើនហៅថា «ស្ទឹងលិង្គ១០០០» មានរូបចំលាក់លិង្គចំនួន១០៥៤ (តាមសិលាចារឹក) ឆ្លាក់លើផ្ទាំងថ្មតាមបាតស្ទឹងសៀមរាប។ គេឆ្លាក់លិង្គដ៏ច្រើនសន្ធឹកទាំងនោះ ដើម្បីអោយអំនាចលិង្គសំអាតទឹក មុនពេលវាហូរទៅដល់ទីក្រុង ដែលនៅខាងក្រោម ហើយដែលប្រើទឹកនោះ។



នៅសម័យនោះ ទ្វីបអឺរ៉ុបបានត្រូវបែងចែកជារាជាណាចក្រច្រើន ដែលធ្វើចំបាំងតទល់គ្នា។ នៅឆ្នាំ៨០០ ព្រះបាទសាលម៉ាញឡើងសោយរាជ្យនៅលើពិភពខាងលិច។

# យសោវរ្ម័នទី១-ស្ថាបនិកទី១នៃក្រុងអង្គរ

៨៨៩-៩០០

**សាកល្បង រកចំលើយ**

ដើម្បីទស្សនាព្រះអាទិត្យអស្តង្គត ទេសចរច្រើនឡើងទៅ

- លើកំពូលភ្នំបាខែង ?
- លើកំពូលភ្នំក្រោម ?
- លើប្រាសាទអង្គរ ?

ចំលើយ : ទំព័រ៤៤

ភ្នំបាខែងបច្ចុប្បន្ន : ជណ្តើរឡើងទៅកាន់ប្រាសាទនៅលើកំពូលភ្នំ។ គេអាចជិះដំរីឡើងផងដែរ។



**ព្រះបាទយសោវរ្ម័នទី១ជាអ្នកចាប់ផ្តើមកសាងក្រុងអង្គរ ដែលបានស្ថិតនៅជារាជធានីខ្មែរ អស់រយៈពេល៦សតវត្ស។**

ព្រះបាទយសោវរ្ម័នទី១ ជាបុត្រារបស់ព្រះបាទឥន្ទ្រវរ្ម័នទី១។ បន្ទាប់ពីបានឡើងសោយរាជ្យស្នងព្រះបិតា ព្រះអង្គបានលើករាជធានីពីហរិហរាល័យមកបង្កើតទីក្រុងថ្មី គឺក្រុងអង្គរ ដែលទ្រង់អោយឈ្មោះថា ក្រុងយសោធរបុរៈ។ នៅលើកំពូលភ្នំតូចមួយឈ្មោះភ្នំបាខែង ទ្រង់បានចាត់អោយសាងសង់ប្រាសាទភ្នំបាខែងសំរាប់ប្រារព្ធធ្វើពិធីទេវរាជ។ នៅខាងក្រោមគឺជាទីក្រុង ដែលលាតសន្ធឹងតាមជើងភ្នំ ហើយមានទឹកហ៊ុមព័ទ្ធជុំវិញ។ ទឹកនេះ ទ្រង់បានបង្វែរទឹកស្ទឹងសៀមរាបបញ្ចូលមក។ គេបានលើកផ្លូវថ្នល់មួយតភ្ជាប់ក្រុងយសោធរបុរៈទៅក្រុងហរិហរាល័យ ដែលជារាជធានីមុន។ ដើម្បីជាប្រយោជន៍ដល់កសិកម្ម ទ្រង់បានសាងបារាយណ៍មួយធំ ដែលមានបណ្តោយ៧គមនិងទទឹង១,៨គម : នោះគឺបារាយណ៍ខាងកើត (ឈ្មោះដើមយសោធរតដាក)។ ព្រះអង្គបានធ្វើអោយវិស័យសាសនានិងជីវភាពបញ្ញាវីកចំរើនយ៉ាងខ្លាំង។ អាវាមជាច្រើនបានត្រូវសាងសង់ឡើងសំរាប់អ្នកកាន់គណៈព្រះសិវៈ គណៈព្រះវិស្ណុ និងព្រះពុទ្ធសាសនា។ នៅពេលព្រះអង្គចូលទិវង្គតនៅគ.ស.៩០០ បុត្រាព្រះអង្គទាំងពីរបានឡើងសោយរាជ្យជាបន្តបន្ទាប់រហូតដល់ឆ្នាំ៩២៨។ នៅឆ្នាំ៩២១ ព្រះបិតុលាព្រះនាមជ័យវរ្ម័នទី៤បានដេករាជ្យ ហើយទៅតាំងរាជធានីថ្មីនៅកោះកេរ្តិ៍ចំងាយប្រមាណ៧០គម នៅទិសឦសាននៃភូមិភាគអង្គរ។ នៅកោះកេរ្តិ៍ ព្រះរាជាអង្គនេះបានសាងប្រាសាទភ្នំធំស្កឹមស្កៃមួយ (ដែលមានទៀប៧ជាន់ និងកំពស់៣៥ម) សំរាប់តំកល់សិវលិង្គ ព្រមទាំងប្រាសាទជាច្រើនទៀត និងបារាយណ៍មួយហៅថាបារាយណ៍រាហាល់ សំរាប់យកទឹកប្រើប្រាស់។



# រាជេន្ទ្រវរ្ម័នទី២-ការត្រលប់មកអង្គរវិញ

៩៤៤-៩៦៨



**ព្រះបាទរាជេន្ទ្រវរ្ម័នទី២បានឡើងសោយរាជ្យបន្តពីបុត្រាព្រះបាទជ័យវរ្ម័នទី៤ ហើយបានពង្រីងវឌ្ឍអំនាចចក្រភពអង្គរបន្ថែមទៀត។**

រាជេន្ទ្រវរ្ម័នទី២ជាក្មួយព្រះបាទយសោវរ្ម័នទី១។ ទ្រង់បានឡើងគ្រងរាជសម្បត្តិនៅឆ្នាំ៩៤៤ រួចលើករាជធានីពីកោះកេរ្តិ៍មកក្រុងយសោធរបុរៈវិញ។ ព្រះអង្គបានប្រកាសថា ទ្រង់ជាប់ពូជពង្សជាមួយអតីតញាតិវង្សនគរចេនឡា។ ព្រះរាជាបានពង្រឹងអំនាចគ្រប់គ្រងរបស់ខ្មែរ : ទ្រង់បានធ្វើចំបាំងប្រមូលក្សត្របរិវារស្វយ័តអោយមកចុះចូលក្រោមឱវាទព្រះអង្គ បង្កើតរដ្ឋបាលកណ្តាលនៅក្រុងអង្គរ ព្រមទាំងបញ្ជូនមន្ត្រីរាជការទៅកាន់អាណាខេត្តនានា។ បន្តិចម្តងៗ ប្រទេសជាតិក៏បានស្គាល់សន្តិភាព និងវិបុលភាព។ ព្រះអង្គបានធ្វើសឹកសង្គ្រាមនិងជនជាតិចាម ដែលទទួលអរិយធម៌ឥណ្ឌាដែរ។ កងទ័ពខ្មែរ ដែលខ្លាំងពូកែជាង បានចូលលុកលុយនគរចាម្ប៉ា ហើយបាននាំយករូបបដិមាធ្វើអំពីមាសមកតំកល់ទុកនៅក្រុងអង្គរ។ ជាមួយគ្នានោះ ព្រះរាជាតែងប្រោសប្រណីចំពោះអ្នកកាន់ព្រះពុទ្ធសាសនា។ ក្នុងរាជ្យព្រះអង្គ មានការកសាងប្រាសាទជាច្រើន ដូចជាប្រាសាទមេបុណ្យខាងកើត ប្រាសាទប្រែរូប ផ្នែកខ្លះនៃប្រាសាទភិមានអាកាស។ ឯព្រាហ្មណ៍ឈ្មោះយជ្ញវរាហៈ ដែលជាព្រះរាជគ្រូបានកសាងប្រាសាទបន្ទាយស្រី នៅខាងជើងក្រុងយសោធរបុរៈនៅគ.ស.៩៦៧ គឺមុនពេលព្រះរាជាទ្រង់សោយទិវង្គតមួយឆ្នាំ។



ប្រាសាទមេបុណ្យខាងកើត



ប្រាសាទបន្ទាយស្រី : ចំលាក់មានវិចិត្រភាពរស់រវើក។

# សូរ្យវរ្ម័នទី១-ស្តេចពុទ្ធសាសនិកទី១ នៃសម័យអង្គរ

១០០២-១០៥០



ព្រះបាទសូរ្យវរ្ម័នទី១បានឡើងសោយរាជ្យនៅឆ្នាំ១០០២ ក្រោយពីបានទទួលជ័យជំនះលើគូប្រជែងក្នុងជំលោះដណ្តើមរាជសម្បត្តិ។

នៅពេលព្រះបាទរាជេន្ទ្រវរ្ម័នទី២សុគតទៅ បុត្រារបស់ព្រះអង្គគឺជ័យវរ្ម័នទី៥ឡើងសោយរាជ្យបន្តដោយមានវ័យក្មេងណាស់នៅឡើយ។ ដូចក្នុងរជ្ជកាលមុនៗដែរ ព្រះអង្គកាន់សាសនាព្រាហ្មណ៍ តែអនុញ្ញាតអោយមានការគោរពបូជាព្រះពុទ្ធសាសនា។ ព្រះអង្គបានកសាងប្រាសាទភ្នំមួយ គឺប្រាសាទតាកែវ តែពុំទាន់បានរួចស្រេចទេ។ នៅពេលទ្រង់ចូលទិវង្គត ការប្រយុទ្ធគ្នាដណ្តើមរាជសម្បត្តិក៏កើតមានឡើង។ ក្រោយមក ព្រះបាទសូរ្យវរ្ម័នទី១បានទទួលជ័យជំនះលើក្សត្រមួយអង្គទៀតជាគូប្រជែង។ ទ្រង់បានទទួលរាជាភិសេកនៅអង្គរហើយរៀបចំអោយមានសន្តិភាពឡើងវិញ។ ប្រទេសជាតិរីកចំរើន ចំនួនប្រជាជនកើនឡើងច្រើន។ អំនាចព្រះរាជាគ្របដណ្តប់ទៅលើវាលទំនាបទន្លេមេណាមទាំងមូល។ គេបានរកឃើញសិលាចារឹករបស់ខ្មែរទាក់ទងនឹងព្រះអង្គនៅតំបន់ល្វោ (លពបុរី) ខាងជើងក្រុងបាងកកសព្វថ្ងៃ។ អំនាចកណ្តាលរបស់ក្រុងអង្គរក្នុងផ្នែកនយោបាយនិងសាសនា មានកំលាំងរឹងមាំឡើងជាលំដាប់។ ព្រះអង្គជាព្រះរាជាទី១នៃសម័យអង្គរ ដែលកាន់ពុទ្ធសាសនាមហាយាន។ ប៉ុន្តែនៅក្នុងព្រះនគរ អ្នកកាន់សាសនាព្រាហ្មណ៍និងអ្នកកាន់ពុទ្ធសាសនារួមរស់សុខសាន្តជាមួយគ្នា។ ព្រះបាទសូរ្យវរ្ម័នទី១បានកសាងប្រាសាទនៅច្រើនកន្លែងដូចជា ប្រាសាទភ្នំជីសូរ (ខេត្តតាកែវ) ផ្នែកខ្លះនៃប្រាសាទព្រះវិហារ... សាងបង្ហើយប្រាសាទភិមានអាកាស និងប្រាសាទតាកែវ។

ប្រាសាទភិមានអាកាស



ប្រាសាទតាកែវ

### សំណាញ់ដឹងទេថា

ដើម្បីពង្រឹងអំនាចរបស់ទ្រង់ ព្រះបាទសូរ្យវរ្ម័នទី១ បានតំរូវអោយមន្ត្រីទាំងឡាយធ្វើសច្ចាប្រណិធានថាស្មោះត្រង់នឹងព្រះអង្គ។



# ឧទយាទិត្យវរ្ម័នទី២ ១០៥០-១០៦៦ ហស៊ីវរ្ម័នទី៣ ១០៦៦-១០៨០ និង ជ័យវរ្ម័នទី៦ ១០៨០-១១០៧

ក្នុងរយៈពេល៥៧ឆ្នាំ (១០៥០-១១០៧) នៅអង្គរមានព្រះរាជាបីអង្គឡើងសោយរាជ្យជាបន្តបន្ទាប់។ សង្គ្រាមប្រឆាំងបរទេស និងចលាចលកើតមានឡើងជាហូរហែ ប៉ុន្តែសំនង់ធំៗមួយចំនួន ក៏បានសំរេចឡើងដែរ។

នៅពេលព្រះបាទសូរ្យវរ្ម័នទី១ចូលទិវង្គតទៅ បុត្រារបស់ព្រះអង្គព្រះនាមឧទយាទិត្យវរ្ម័នទី២និងហស៊ីវរ្ម័នទី៣ បានឡើងសោយរាជ្យជាបន្តបន្ទាប់។ ឧទយាទិត្យវរ្ម័នទី២បានសាងប្រាសាទបាពួន បារាយណ៍ខាងលិច រឺបារាយណ៍ទឹកថ្លា (៨គម x ២,២គម) និងប្រាសាទមេបុណ្យខាងលិច។ ឯព្រះអនុជព្រះនាមហស៊ីវរ្ម័នទី៣បានធ្វើចំបាំង២លើក។ លើកទី១ ខ្មែរត្រូវច្បាំងប្រឆាំងពួកចាម ដែលលើកទ័ពចូលមកវាយខ្មែរហើយកៀរខ្មែរយកទៅជាឈ្លើយ។ លើកទី២ ដោយការអូសទាញរបស់ចិន ខ្មែរបានលើកទ័ពទៅវាយពួកដៃវៀត ដោយរួមកំលាំងជាមួយចាម។ ប៉ុន្តែទ័ពខ្មែរនិងចាមបានដកថយវិញ។ នៅឆ្នាំ១០៨០ ព្រះបាទជ័យវរ្ម័នទី៦ប្រកាសខ្លួនជាស្តេចផែនដី តែពុំមកសោយរាជ្យនៅអង្គរទេ។ ព្រះអង្គគង់នៅរាជធានីថ្មីឈ្មោះមហីធរបុរៈ ក្នុងទំនាបទន្លេមូល។ ទ្រង់បានសាងប្រាសាទភ្នំសណ្តក ប្រាសាទភិម៉ៃ (សព្វថ្ងៃនៅក្នុងទឹកដីថៃ) ប្រាសាទវត្តភូ (សព្វថ្ងៃនៅក្នុងទឹកដីឡាវ)។ នៅចុងរាជ្យព្រះអង្គនិងបន្តមកទៀត ចលាចលកើតមានឡើងច្រើនលើក។ លុះដល់ដើមស.វ.ទី១២ ទើបព្រះបាទសូរ្យវរ្ម័នទី២ឡើងសោយរាជ្យនៅអង្គរ ហើយធ្វើអោយមានរបៀបរៀបរយឡើងវិញ។



**ព្រះវិស្ណុធំ**
នៅកណ្តាលបារាយណ៍ខាងលិច រឺបារាយណ៍ទឹកថ្លា មានប្រាសាទមេបុណ្យខាងលិច ដែលកាលពីដើមមានតំកល់បដិមាព្រះវិស្ណុធំ។



ប្រាសាទវត្តភូ (សព្វថ្ងៃនៅក្នុងប្រទេសឡាវ) កសាងនៅស.វ.ទី១១ ដោយ ព្រះបាទជ័យវរ្ម័នទី៦

### សំណាញ់ដឹងទេថា

បារាយណ៍ជាអាងធំៗ ដែលមនុស្សកសាងឡើងដើម្បីផ្ទុកទឹកសំរាប់ប្រើប្រាស់ក្នុងវិស័យកសិកម្ម។ គេលើកដីជាទំនប់ព័ទ្ធដីមួយកន្លែងតាមជ្រុងទាបៗរបស់វា។ បារាយណ៍មានទឹកដោយសារភ្លៀង និងទឹកស្ទឹង ដែលគេបង្ហូរចូលតាមជ្រុងខ្ពស់របស់វា។ ដោយផ្ទៃទឹកនៅក្នុងបារាយណ៍ខ្ពស់ជាងទំនាបជុំវិញ គេគ្រាន់តែជីករង្វះមួយកាត់ទំនប់តាមជ្រុងទាប ទឹកក៏ហូរខ្លួនឯងចូលទៅតាមប្រលាយតូចៗ រហូតដល់ស្រែ។

# សូរ្យវរ្ម័នទី២-អ្នកកសាងប្រាសាទអង្គរវត្ត

## ១១១៣-១១៥០



កងទ័ពព្រះបាទសូរ្យវរ្ម័នទី២ (ថែវអង្គរវត្ត)

**បន្ទាប់ពីបានកំចាត់គូប្រជែងពីរាជធានីអង្គរ ព្រះបាទសូរ្យវរ្ម័នទី២ បានទទួលពិធីអភិសេកជាស្តេចផែនដី នៅឆ្នាំ១១១៣។**

រជ្ជកាលព្រះបាទសូរ្យវរ្ម័នទី២ បានត្រូវកត់សំគាល់ជាពិសេសដោយការសាងសង់ប្រាសាទអង្គរវត្ត ដែលជាប្រាសាទមានឈ្មោះល្បីល្បាញនៅលើពិភពលោក។ ក្នុងផ្នែកសឹកសង្គ្រាម កងទ័ពដ៏ខ្លាំងពូកែរបស់ព្រះអង្គបានចេញទៅច្បាំងច្រើនលើកច្រើនសាទឹងពួកដៃវៀតនិងពួកចាម នៅទិសខាងកើត។ ឯនៅទិសខាងលិច ទ័ពខ្មែរបានរុញច្រានការជ្រៀតចូលរបស់កងទ័ពភូមា។ ជាមួយគ្នានេះ ដើម្បីភ្ជាប់ចំនងមិត្តភាពជាមួយចិន ព្រះអង្គបានបញ្ជូនរាជទូតច្រើនលើកទៅគាល់អធិរាជចិន។ នៅពេលព្រះអង្គសោយទិវង្គតទៅ រាជាណាចក្រខ្មែរមានផ្ទៃដីធំទូលាយ លាតសន្ធឹងពីប្រទេសចិនរហូតដល់សមុទ្រ និងពីរាជាណាចក្រភូមាដល់នគរចាម្ប៉ា។ ប៉ុន្តែនៅក្នុងវាំងវិញ ពួកព្រាហ្មណ៍មិនសូវសប្បាយចិត្តទេ។ អស់មួយរយៈពេលមកហើយ ដែលពួកគេសង្កេតឃើញថា ព្រះពុទ្ធសាសនាកាន់តែរីកសុសសាយ រហូតអាចបង្កគ្រោះថ្នាក់ដល់សាសនាព្រាហ្មណ៍។ ពួកគេក៏ពង្រឹងអំនាចរបស់ខ្លួន ហើយបានទទួលអំនោយនិងឯកសិទ្ធិជាច្រើន រហូតជួនកាលពួកគេអាចសំរេចភាពស្របច្បាប់របស់ព្រះរាជាទៀតផង។ ទន្ទឹមគ្នានេះ ដើម្បីពង្រឹងអំនាចរបស់ទ្រង់ ព្រះអង្គបានចាត់អោយមានមូលនិធិច្រើនឡើងថែមទៀត សំរាប់ទ្រទ្រង់គណៈព្រះសិវៈ និងគណៈព្រះវិស្ណុ។ ក្នុងវិស័យសំនង់ ព្រះអង្គបានបន្តកសាងប្រាសាទភ្នំជីសូរ ប្រាសាទវត្តភូ ប្រាសាទព្រះវិហារ។ ឯសំនង់ថ្មីមាន ប្រាសាទព្រះពិធូរ ចៅសាយទេវតា បន្ទាយសំរែ...។ ប៉ុន្តែស្នាព្រះហស្តចំបងរបស់ព្រះអង្គគឺ ប្រាសាទអង្គរវត្ត ដែលជាស្នាដៃពិសិដ្ឋមិនអាចកាត់ថ្លៃបាន និងជាបេតិកភណ្ឌពិភពលោក។

ព្រះបាទសូរ្យវរ្ម័នទី២ និងរាជបរិវារ (តាមចំលាក់នៅថែវប្រាសាទអង្គរវត្ត)







ការសាងសង់ប្រាសាទអង្គរវត្ត



### សំណាញ់និងមេថា

ថ្មភក់ ដែលគេបានយកមកសាងសង់ប្រាសាទនៅអង្គរ បានត្រូវជីកយកពីភ្នំគូលែន និងដឹកជញ្ជូនមកតាមស្ទឹងសៀមរាប។

# ប្រាសាទអង្គរវត្ត

ប្រាសាទអង្គរវត្តជាស្នាដៃឯកនៃសិល្បៈខ្មែរ ស្ថាបនាឡើងនៅពាក់កណ្តាលខាងដើមនៃ ស.វ.ទី១២ ក្នុងរាជ្យព្រះបាទសូរ្យវរ្ម័នទី២។ ប្រាសាទនេះបានត្រូវជ្រើសយកធ្វើជានិមិត្តរូបប្រជាជាតិខ្មែរ ដូចមានរូបនៅលើទង់ជាតិប្រទេសកម្ពុជា ជាសក្ខីភាព។



**ពត៌មានខ្លីៗពីប្រាសាទអង្គរវត្ត :**

- ▶ ទីតាំង : ៦ គមពីក្រុងសៀមរាប។
- ▶ សាងសង់ : ពាក់កណ្តាលទី១នៃស.វ.ទី១២។
- ▶ ក្សត្រស្ថាបនិក : សូរ្យវរ្ម័នទី២
- ▶ ឧទ្ទិសចំពោះ : ព្រះវិស្ណុ ក្នុងសាសនាព្រាហ្មណ៍។
- ▶ ភិនភាគ : ជាប្រាសាទភ្នំ មាន៣ថ្នាក់ កំពែង៤ជាន់ កំពូល កណ្តាលកំពស់ ៦៥ម។
- ▶ សង់អំពី : ថ្មភក់ និងថ្មបាយក្រៀម។
- ▶ គូទឹកព័ទ្ធជុំវិញ : មានទទឹងប្រវែង ១៩០ម។
- ▶ រូបចំលាក់ : មានជាផ្ទាំងធំៗវែងៗ រចនាជារឿងផ្សេងៗពីគ្នា។



ថែវយ៉ាងវែងមានចំលាក់នៅលើជញ្ជាំងប្រាសាទអង្គរវត្ត

## សំណាញ់ដឹងទេថា

ថ្មីៗនេះ អ្នកស្រាវជ្រាវខ្លះបានរកឃើញថា ខ្មែរនៅសម័យអង្គរបានប្រើប្រាសាទអង្គរវត្តធ្វើជាកន្លែងសំរាប់អោយអ្នកតារាវិទ្យាពិនិត្យមើលចលនាព្រះអាទិត្យ ព្រះចន្ទ និងផ្កាយ។

## សាកល្បងរកចំលើយ

ប្រាសាទអង្គរវត្តបែរមុខ :

- ▶ ទៅលិច ?
- ▶ ទៅកើត ?
- ▶ ទៅជើង ?

ចំលើយ : ទំព័រ៤៤

# ការជ្រួលច្របល់នៅស.វ.ទី១២ និងការវាយលុករបស់ចាម

**ការប្រយុទ្ធរវាងបុត្រាព្រះបាទជ័យវរ្ម័ន និងរាហូ**

នៅពេលភារតៈរាហូបញ្ចេញគំនិតក្បត់ប្រឆាំងព្រះបាទយសោវរ្ម័នទី២ កងទ័ពទាំងឡាយនៅក្នុងក្រុង បានលបរត់ចេញអស់។ ក្សត្រា ដែលត្រូវជាបុត្ររបស់ជ័យវរ្ម័ន ក៏ចេញប្រយុទ្ធ។ សេនា២នាក់ជួយព្រះអង្គ និងរួមដៃគ្នាប្រយុទ្ធ។ ព្រះអង្គវាយភារតៈរាហូត្រូវចំច្រមុះ ហើយរាហូក៏ដួលដេកទៅ។

ក្រោយពេលព្រះបាទសូរ្យវរ្ម័នទី២សោយទិវង្គតទៅ ប្រហែលនៅឆ្នាំ១១៥០ ចក្រភពអង្គរធ្លាក់ទៅក្នុងភាពច្របូកច្របល់ម្តងទៀត ដែលជាហេតុធ្វើអោយពួកចាមវាយលុកចូលអង្គរ។

### ▶ ព្រឹត្តិការណ៍ក្រោយរាជ្យព្រះបាទសូរ្យវរ្ម័នទី២

ព្រះបាទធរណីន្ទ្រវរ្ម័នទី២បានទទួលរាជសម្បត្តិបន្តពីព្រះបាទសូរ្យវរ្ម័នទី២។ ទ្រង់ជាស្តេចនិយមសាសនាព្រះពុទ្ធ ហើយអប់រំបុត្រាព្រះនាមជ័យវរ្ម័ន (អនាគតជ័យវរ្ម័នទី៧) អោយគោរពតាមឱវាទសាសនានេះ។ នៅពេលព្រះបិតាសោយទិវង្គត ក្សត្រជ័យវរ្ម័នគង់នៅឯប្រទេសចាម្ប៉ាឯនោះ កំពុងជាប់រវល់ធ្វើសឹកសង្គ្រាមច្បាំងនិងចាម។ ដូចនេះហើយទើបក្សត្រមួយអង្គនាមយសោវរ្ម័នទី២ (១១៦០–១១៦៥) ឡើងគ្រងរាជ្យទៅវិញ។ ចំណែកក្សត្រជ័យវរ្ម័នទ្រង់យល់ព្រមលះបង់សិទ្ធិរបស់ព្រះអង្គ ហើយស្ម័គ្របំរើស្តេចថ្មីយ៉ាងស្មោះត្រង់។ លើសពីនេះ បុត្រាមួយអង្គរបស់ទ្រង់ហ៊ានពុះពារគ្រោះថ្នាក់ស៊ូប្រថុយជីវិត ដើម្បីជួយស្តេចគ្រងរាជ្យអោយបានរួចពីការវាយលុករបស់



ជនក្បត់ម្នាក់ឈ្មោះរាហូ ដែលប៉ងធ្វើគុតព្រះអង្គ។ ក្រោយមក នៅពេលមានការបះបោរជណ្តើមរាជ្យម្តងទៀត ក្សត្រជ័យវរ្ម័នបានប្រញាប់យាងត្រលប់ពីចាម្ប៉ាមកវិញ ដើម្បីមកជួយសង្គ្រោះព្រះបាទយសោវរ្ម័នទី២ដែរ ប៉ុន្តែទ្រង់មកមិនទាន់ ហើយស្តេចគ្រងរាជ្យអង្គនេះក៏បានត្រូវគេធ្វើគុតទៅ។ ក្សត្រជ័យវរ្ម័នបានដកថយទៅវិញដោយស្ងៀមស្ងាត់ មិនព្រមធ្វើសឹកសង្គ្រាមច្បាំងនិងគ្នាឯងទេ ទ្រង់សញ្ជឹងព្រះទ័យនិងរង់ចាំសិន។




ការវាយលុករបស់ចាម : ទ័ពចាមឡើងតាមទន្លេមេគង្គ ហើយបន្តចូលតាមទន្លេសាប។

### ▶ ពួកចាមវាយយកបានអង្គរ (១១៧៧)

ស្តេចថ្មីនាមត្រីភូវនាទិត្យវរ្ម័ន (១១៦៥–១១៧៧) ដែលជាស្តេចដែលក្រាជ្យត្រូវប្រឈមមុខតទល់និងការឈ្លានពានរបស់ពួកចាម។ កងទ័ពចាមដែលចូលមកវាយខ្មែរលើកទី១តាមផ្លូវគោក បានត្រូវរុញច្រានអោយដកថយទៅវិញ។ ប៉ុន្តែស្តេចចាមនៅមានបំណងបន្តសង្គ្រាមទៀត។ នៅឆ្នាំ១១៧៧ ដោយមាននាវិកជាតិចិនម្នាក់ជួយនាំផ្លូវ ទ័ពចាមបានបើកសំពៅសៀរតាមឆ្នេរសមុទ្រ ហើយបន្តឡើងតាមទន្លេមេគង្គ ចូលតាមទន្លេសាប រួចមកចូលចតនៅត្រើយខាងជើងនៃបឹងទន្លេសាប។ បន្ទាប់មកចំបាំងក៏ផ្ទុះឡើង។ កងទ័ពខ្មែរទទួលបរាជ័យ ហើយស្តេចខ្មែរបានត្រូវធ្វើគុតក្នុងសមរភូមិ។ ចាមចូលលុកលុយអង្គរ កាប់សំលាប់ និងឆក់ប្លន់ទ្រព្យសម្បត្តិ។ គឺនៅក្នុងកាលៈទេសៈលំបាកដូចនេះហើយ ដែលក្សត្រជ័យវរ្ម័នទ្រង់ចេញមុខដឹកនាំការតស៊ូរំដោះជាតិ រហូតដល់ទទួលបានជ័យជំនះទាំងស្រុង។

**ស្តេចចាម**

ស្តេចរបស់ពួកចាម អួតអាងឫទ្ធានុភាពដូចជាក្រុងរាពណ៍ តាំងលើកទ័ពដោយរាជរថឆ្ពោះមកច្បាំងនឹងប្រទេស (កម្ពុជា) ដែលជាប្រទេសល្អឧបមាបីដូចជាឋានសួគ៌...
(ចារឹកនៅភិមានអាកាស)

នៅសម័យនោះ ពួកអ្នកកាន់សាសនាគ្រិស្តនៅទ្វីបអឺរ៉ុបវាយលុកទៅលើពួកអ៊ីស្លាមនៅឯសមុទ្រមេឌីទែរ៉ាណេ។ គេហៅពលទាហាន ដែលចេញទៅច្បាំងទាំងនោះថា បូជនីយជន។



# ជ័យវរ្ម័នទីពា-មហាក្សត្រកំពូល

## ១១៨១-ប្រហែល១២១៨

**ព្រះបាទជ័យវរ្ម័នទី៧បានវាយកំចាត់ពួកចាមចេញអស់ពីអង្គរ និងបានកសាងប្រទេសជាតិអោយរីកចំរើនរុងរឿងលើគ្រប់វិស័យ ធ្វើអោយអរិយធម៌ខ្មែរឡើងដល់កំរិតកំពូល។**

### ▶ ស្តេចចំបាំង

ការប្រយុទ្ធរំដោះទឹកដីត្រូវការរយៈពេល៤ឆ្នាំ។ ក្សត្រជ័យវរ្ម័នដឹកនាំទ័ពប្រយុទ្ធយ៉ាងស្វិតស្វាញប្រឆាំងកងទ័ពចាមឈ្លានពាន ហើយបានទទួលជ័យជំនះជាបន្តបន្ទាប់។ នៅទីបំផុត ព្រះអង្គបានទទួលជោគជ័យជាស្ថាពរលើពួកចាម ក្នុងចំបាំងជើងទឹកមួយនៅលើបឹងទន្លេសាប។ ប្រទេសកម្ពុជាបានត្រូវរំដោះមកវិញ។ ព្រះអង្គបានទទួលរាជាភិសេកឡើងសោយរាជ្យនៅអង្គរក្នុងជន្មាយុ៥៦វស្សា ដោយមានព្រះនាមថាព្រះបាទជ័យវរ្ម័នទី៧។ បន្ទាប់មកព្រះរាជាណាចក្រកម្ពុជាក៏បានស្គាល់ភាពរីកចំរើនរុងរឿង។ ស្តេចអង្គនេះមានព្រះជាយាានាមជ័យរាជទេវី។ ស្វាមីនិងមហេសីស្រលាញ់គ្នាណាស់ ហើយមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនាដូចគ្នា។ បន្ទាប់ពីព្រះនាងជ័យរាជទេវីសុគតទៅ ព្រះរាជាក៏រៀបអភិសេកជាមួយព្រះនាងឥន្ទ្រទេវី ដែលត្រូវជាបងស្រីបង្កើតរបស់ព្រះនាងជ័យរាជទេវី។ ព្រះនាងឥន្ទ្រទេវីជាស្ត្រីអ្នកប្រាជ្ញ មានវប្បធម៌ខ្ពង់ខ្ពស់ និងជាអ្នកមានចំនេះវិជ្ជាជ្រៅជ្រះខាងទស្សនវិជ្ជា។ ព្រះនាងជាសាស្ត្រាចារ្យក្នុងវត្តពុទ្ធសាសនាមួយ ហើយបានកសាងសិលាចារិកភិមានអាកាស ដែលនិយាយពីជីវប្រវត្តិរបស់ស្តេចជ័យវរ្ម័នទី៧។ ព្រះបាទជ័យវរ្ម័នទី៧មានមន្ត្រីល្អៗ និងស្មោះត្រង់ជាច្រើនរូប រួមទាំងស្តេចចាមឈ្មោះវិទ្យានន្ទន៍ផងនៅរង់ចាំបំរើ។ គឺដោយក្តីស្វាមីភក្តិរបស់ពួកគេទាំងអស់នោះហើយ ទើបព្រះអង្គអាចស្តារ និងកសាងប្រទេសជាតិឡើងវិញបាន។

ព្រះកេសព្រះបាទជ័យវរ្ម័នទី៧

**ព្រះនាងជ័យរាជទេវី**

« ជលនេត្របាយរហាម ព្រះនាងយំសោកដូចនាងសីតានឹកដល់ស្វាមី ដែលឃ្លាតទៅឆ្ងាយ... ដោយបានទទួលការបង្ហាត់បង្រៀនពីបងស្រីឈ្មោះឥន្ទ្រទេវី និងដោយចិត្តស្មោះសរគោរពបូជាចំពោះព្រះពុទ្ធជាទីស្រលាញ់បំផុតនៃសេចក្តីប្រាថ្នាទាំងឡាយ ព្រះនាងប្រកាន់យកផ្លូវស្ងប់ស្ងាត់របស់មនុស្សមានគតិបណ្ឌិត ដែលដើរចន្លោះភ្លើងទារុណកម្មនិងសមុទ្រទុក្ខ។ »



ចំពោះពួកចាម ដែលបានចូលមកវាយបំផ្លិចបំផ្លាញនិងកាន់កាប់ក្រុងអង្គរក្នុងឆ្នាំ១១៧៧នោះ ព្រះបាទជ័យវរ្ម័នទី៧សំរេចថានឹងធ្វើការសងសឹកវិញអោយបាន។ ជាច្រើនឆ្នាំមកហើយ ទ្រង់បានគង់នៅដោយស្ងៀមស្ងាត់ និងអត់ធន់។ ឥឡូវដល់ពេលព្រះអង្គចេញវាយលុកហើយ។ ជាដំបូងព្រះអង្គទ្រង់បានធ្វើអោយប្រទេសដៃវៀតនៅអព្យាក្រឹត។ បន្ទាប់មកទ្រង់បញ្ជូនទ័ពក្រោមបញ្ជាក្សត្រចាមឈ្មោះវិទ្យានន្ទន៍ អោយទៅវាយនគរចាម្ប៉ា។ ទ័ពខ្មែរវាយបែកបានក្រុងវិជ័យ ដែលជារាជធានីនគរចាម្ប៉ា។ ព្រះអង្គលើកព្រះអង្គម្ចាស់អិនអោយសោយរាជ្យនៅក្រុងវិជ័យ។ ក្រោយមកពួកចាមនៅវិជ័យបះបោរឡើង វិទ្យានន្ទន៍បង្រ្កាបបានរួចមានគំនិតក្បត់ ហើយប្រកាសខ្លួនឯងជាស្តេចនគរចាម្ប៉ាទាំងមូល។ ដោយពុំអាចអូសទាញវិទ្យានន្ទន៍អោយមកនៅក្រោមឱវាទរបស់ទ្រង់បាន ព្រះបាទជ័យវរ្ម័នទី៧ក៏បញ្ជូនទ័ពអោយទៅកំចាត់វិទ្យានន្ទន៍ចោល។ បន្ទាប់មកនគរចាម្ប៉ាក្លាយជាអាណាខេត្តខ្មែរអស់រយៈពេលប្រមាណ១៧ឆ្នាំ។ នៅគ.ស.១២០៧ ព្រះបាទជ័យវរ្ម័នទី៧ បានបញ្ជាអោយស្តេចចាមមួយអង្គទៀតនាមអង្សរាជលើកទ័ពទៅវាយប្រទេសដៃវៀតទៀត។ ក្នុងរាជ្យព្រះអង្គ ចក្រភពខ្មែរមានវិសាលភាពធំធេងណាស់។ នៅក្នុងសឹកសង្គ្រាមទាំងអស់ ព្រះបាទជ័យវរ្ម័នទី៧បានប្រកាន់យកភាពតឹងរ៉ឹងមោះមុតផង និងការសន្តោសអធ្យាស្រ័យផង ចំពោះអ្នកចាញ់។ ចំពោះមនុស្សគ្រប់រូបព្រះអង្គមានចិត្តស្រលាញ់និងអាណិតអាសូរ ដោយយោងតាមគុណធម៌ចំបងរបស់ព្រះពុទ្ធសាសនា គឺមេត្តាធម៌។

ជ័យវរ្ម័នទី៧ កំពុងដឹកនាំកងទ័ព (ថែវប្រាសាទបាយ័ន)។



ចំបាំងជើងទឹកប្រឆាំងចាម (ថែវខាងក្រៅប្រាសាទបាយ័ន)



ព្រះនាងជ័យរាជទេវី

## ▶ ស្តេចពុទ្ធសាសនិកដ៏ឆ្នើម



សាលាសំនាក់ នៅប្រាសាទព្រះខាន់។ គេគិតថា នៅជុំវិញមានផ្ទះតូចៗសង់ពីឈើសំរាប់អោយអ្នកដំនើរស្នាក់។

ព្រះបាទជ័យវរ្ម័នទី៧ជាមហាក្សត្រកាន់សាសនាព្រះពុទ្ធ (មហាយាន) យ៉ាងខ្ជាប់ខ្ជួន។ ព្រះអង្គតែងមានសេចក្តីមេត្តាករុណា តាមការប្រៀនប្រដៅរបស់ព្រះពុទ្ធ។ នេះគឺជាគុណធម៌ ដែលព្រះរាជាត្រូវមានដើម្បីបំពេញរាជកិច្ច។ ព្រះអង្គតែងគិតដល់ប្រជារាស្ត្រ ដែលមានក្តីលំបាក។ ព្រះអង្គបានអោយគេសាងសង់មន្ទីរពេទ្យជាច្រើននៅទូទាំងប្រទេស។ សិលាចារឹកមួយប្រាប់ថាមន្ទីរពេទ្យទាំងអស់មានចំនួន១០២កន្លែង។ មន្ទីរពេទ្យទាំងនោះមានថ្នាំសង្កូវគ្រប់គ្រាន់ ព្រមទាំងគ្រូឱសថបុរាណជំនាញជាច្រើននាក់ទៀតផងសំរាប់ទទួលព្យាបាលអ្នកជំងឺគ្រប់ជាន់ថ្នាក់។ ព្រះបាទជ័យវរ្ម័នទី៧បានបញ្ជាអោយលើកផ្លូវថ្នល់ជាច្រើនខ្វាត់ខ្វែងពាសពេញប្រទេស ពិសេសពីអង្គរទៅភិម៉ៃ (ភិម៉ៃសព្វថ្ងៃនៅក្នុងទឹកដីថៃ) និងពីអង្គរទៅចាម្ប៉ា។ លើសពីនេះ នៅមានស្ពានធំៗព្រមទាំងសាលាសំនាក់ជាច្រើនសំរាប់អ្នកដំនើរនិងបុជនីយេសក៏។ សាលាសំនាក់នៅទូទាំងប្រទេសមានចំនួន១២១ស្ថិតនៅហូរហែតាមផ្លូវធំៗ ឃ្លាតគ្នាពីមួយទៅមួយប្រហែលពី១២ទៅ១៥គម គឺស្មើនឹងចំងាយផ្លូវដែលអ្នកធ្វើរជើងអាចដើរបានក្នុង៤ រឺ៥ម៉ោង។ នៅសាលាសំនាក់ទាំងនោះ អ្នកដំនើរអាចចំអិនអាហារហូបចុក និងសំរាកនៅពេលយប់។ ព្រះបាទជ័យវរ្ម័នទី៧មានសន្តានចិត្តបុណ្យ និងគោរពចំពោះមាតាបិតាព្រះអង្គណាស់។ ដើម្បីឧទ្ទិសដល់វិញ្ញាណក្ខន្ធអ្នកមានគុណទាំងទ្វេទ្រង់បានកសាងប្រាសាទនិងវត្តអារាមជាច្រើន : ប្រាសាទតាព្រហ្មឧទ្ទិសចំពោះព្រះមាតា ឯប្រាសាទព្រះខាន់ថ្វាយដល់ព្រះបិតា។ ការត្រាប្រណី ដែលជាគុណធម៌មួយទៀតនៃពុទ្ធសាសនា បានបើកអោយព្រះអង្គរក្សាទុកមុខងារសំខាន់ៗដល់ពួកព្រាហ្មណ៍។ ពួកព្រាហ្មណ៍បន្តរស់នៅក្នុងរាជវាំង នៅទទួលការរាប់អាន និងនៅមានឋានៈជាវរជនចាំបាច់ខាននមិនបានក្នុងការរៀបចំពិធីតាមបែបព្រាហ្មណ៍សាសនា។ ព្រាហ្មណ៍ខ្លះបានធ្វើដំនើរមកពីទីឆ្ងាយ ដើម្បីមកសុំបំរើព្រះអង្គ។ ព្រះអង្គមានទឹកចិត្តល្អ ស្រលាញ់ប្រជារាស្ត្រ មានការរំជួលចិត្តចំពោះទុក្ខលំបាក និងសេចក្តីឈឺចាប់របស់ប្រជារាស្ត្រ។ សិលាចារឹកនៅមន្ទីរពេទ្យរបស់ព្រះអង្គចែងថា : «ជំងឺរបស់ប្រជារាស្ត្រ ធ្វើអោយព្រះអង្គឈឺចាប់ជាងជំងឺផ្ទាល់របស់ព្រះអង្គទៅទៀត»។

### សំណាញ់និងទេចំា

សិលាចារឹកតាព្រហ្មប្រាប់ថាមានមន្ទីរពេទ្យទាំងអស់ចំនួន១០២ នៅទូទាំងប្រទេស។ សព្វថ្ងៃ គេបានរកឃើញមន្ទីរ-ពេទ្យ១៥កន្លែង ដោយសារសិលាចារឹកមួយផ្ទាំងសរសេរជាភាសាសំស្ក្រឹត។



មន្ទីរពេទ្យនៅសម័យនោះ



ប្រាសាទព្រះខាន់

### ព្រះរាជឧទ្ទិស

« ដោយអំនាចអានុភាពរបស់ការដ៏ប្រសើរដែលខ្ញុំបានធ្វើនេះ សូមអោយព្រះវររាជមាតាខ្ញុំពេលទ្រង់រួចផុតពីសមុទ្រសាគរ ពោលគឺពីវដ្តសង្សារ ហើយ បានសំរេចនូវភាវៈជាព្រះពុទ្ធ។ »




ចក្រភពខ្មែរក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧ មានវិសាលភាពធំធេងបំផុតក្នុងប្រវត្តិសាស្ត្រប្រទេសជាតិ។

## ▶ ស្តេចស្ថាបនិក

ព្រះបាទជ័យវរ្ម័នទី៧ ជាស្តេចកសាងសមិទ្ធិច្រើនជាងគេបំផុត។ រាជធានីអង្គរបានត្រូវរៀបចំឡើងវិញ ក្រោយពីពួកចាមបានចូលលុកលុយ និងបំផ្លិចបំផ្លាញ។ ព្រះអង្គកសាងកំពែងថ្មហ៊ុមព័ទ្ធអង្គរធំ ដែលមានរាង៤ជ្រុងស្មើ ប្រវែង៣គម និងកំពស់៨ម ក្នុងមួយជ្រុងៗ។ អង្គរធំមានខ្លោងទ្វារ៤បែរទៅរកទិសទាំង៤ និងមានទ្វារទី៥ហៅថាទ្វារជ័យ ដែលចេញទៅជ្រុងខាងកើត។ ដូចរាជធានីខ្មែរឯទៀតៗដែរ ទីក្រុងនេះមានគូទឹកព័ទ្ធជុំវិញ។ ស្ពានហាល ដែលឆ្លងគូចូលទៅកាន់ប្រាសាទ មានរូបទេវតានិងអសុរទាញនាគធ្វើជាព្រ័ត្រនៅអមសងខាង។ ភ្នំបាខែងរបស់ព្រះបាទយសោវរ្ម័ន លែងជាចំនុចកណ្តាលនៃរាជធានីទៀតហើយ ៖ នៅកណ្តាលបរិវេណថ្មីនេះ ទ្រង់សាងប្រាសាទបាយ័នដើម្បីឧទ្ទិសចំពោះពុទ្ធសាសនាមហាយាន។ បាយ័នមានប្រាង្គសរុបចំនួន៥៤នៅគ្រប់ជាន់ថ្នាក់ ប្រាង្គនីមួយៗមានមុខ៤ប្រកបដោយស្នាមញញឹម។ ឯនៅតាមថែវមានចំលាក់បង្ហាញពីមនុស្សប្រុសស្រីសម័យនោះកំពុងធ្វើការក្នុងជីវិតប្រចាំថ្ងៃ បំរើស្តេច រឺធ្វើសង្គ្រាម-ល-។ ប្រាសាទបាយ័នជាស្នូលនៅចំកណ្តាលទីក្រុង។ មិនឆ្ងាយពីទីនេះប៉ុន្មាន មានប្រាសាទបាពួន បន្ទាប់ទៅទៀតមានព្រះរាជវាំងចាស់លំអដោយព្រលានដំរីនិងព្រលានស្តេចគំលង់ ហើយនៅជិតនោះដែរមានប៉មទាំង១២នៃប្រាសាទសួរព្រ័ត្រ។ នៅជុំវិញទីក្រុង ព្រះបាទជ័យវរ្ម័នទី៧បានបន្សល់ទុកស្នាព្រះហស្តជាច្រើនសំរាប់កូនចៅជំនាន់ក្រោយ ដូចជាប្រាសាទតាព្រហ្ម ព្រះខ័ន ប្រាសាទបន្ទាយក្តីដែលមាន



ប្រាសាទនាគព័ន្ធ នៅកណ្តាលបារាយណ៍ជ័យតដាក ជាកន្លែងសំរាប់ព្យាបាលជំងឺ។





**រចនាបថបាយ័ន**

ព្រះបាទជ័យវរ្ម័នទី៧បានបង្កើតរចនាបថមួយក្នុងសិល្បៈខ្មែរ គឺរចនាបថបាយ័ន ដែលមានប្រាសាទបាយ័នជាតំណាង។ លក្ខណៈរបស់រចនាបថនេះ គឺមានប្រាង្គមុខ៤ ញញឹមទៅរកទិសទាំង៤។

ស្រះស្រង់នៅពីខាងមុខ ប្រាសាទនាគព័ន្ធនៅកណ្តាលអាងទឹក តាសោម ក្រោលគោ។ ប៉ុន្តែព្រះមហាក្សត្រអង្គនេះមិនត្រឹមតែគុបតែងលំអរាជធានីប៉ុណ្ណោះទេ ទ្រង់បានកសាងសំណង់ជាច្រើនទៀតនៅពាសពេញប្រទេស ៖ ប្រាសាទវត្តនគរ (កំពង់ចាម) តាព្រហ្ម (ទន្លេបាទី) បន្ទាយឆ្មារ (បន្ទាយមានជ័យ) និងប្រាសាទផ្សេងៗច្រើនទៀត ដែលសព្វថ្ងៃនេះស្ថិតនៅក្នុងប្រទេសថៃ។ ការកសាងប្រាសាទបន្ទាយឆ្មារ ដែលមានចំលាក់ល្អប្រណិត ប្រហែលជាត្រូវប្រើពលករប្រមាណ ៤៤០០០នាក់ អោយធ្វើការផ្ទាំនិងជាងចំលាក់ប្រមាណ ១០០០ នាក់អោយធ្វើការរយៈពេល ២០ឆ្នាំ (តាមការប៉ាន់ស្មានរបស់លោក ជក គ្រូល្បេ)។ ទ្រង់បានកសាងប្រាសាទជាច្រើនបន្ថែមទៅលើស្នាព្រះហស្តដ៏ធំធេងរបស់មហាក្សត្រមុនៗ ដើម្បីប្រទានដល់មនុស្សជាតិទាំងមូលនូវអរិយធម៌រុងរឿងមួយ ក្នុងចំណោមអរិយធម៌រុងរឿងដទៃទៀតដែលពិភពលោកបានស្គាល់។

**ទីក្រុងយសោធរបុរៈ**

« ទីក្រុងយសោធរបុរៈ ប្រៀបបាននឹងកូនក្រមុំម្នាក់ក្នុងព្រហ្មលល្អ សមធ្នាឥតខ្ចោះនឹងគូសង្សារ ហើយពួលរនេះដោយក្តីព្រាថ្នា លំអដោយប្រាសាទមួយអំពីថ្មមានតំលៃ និងហាក់ដូចជាមានកំពែងជាសំលៀក-បំពាក់ បានត្រូវរៀបការជាមួយស្តេច ដើម្បីបង្កើតសុភមង្គលអោយសត្វលោក ក្នុងពិធីអភិសេកមួយ ក្រោមដំបូលដ៏រុងរឿងនៃជោគជ័យ។ »



ប្រាសាទបន្ទាយឆ្មារ នៅក្នុងខេត្តបន្ទាយមានជ័យ

នៅសម័យជាមួយគ្នានោះ អ្នកកាន់សាសនាគ្រិស្តនៅអឺរ៉ុបចាប់ផ្តើមសាងសង់វិហារគ្រិស្តធំៗ។

# ស្ដេចសោយរាជ្យបន្តពីជ័យវរ្ម័នទី៧

ប្រហែល១២១៨-១៣៣៦

**ព្រះមហាក្សត្រទាំងឡាយ ដែលបានសោយរាជ្យបន្តពីព្រះបាទជ័យវរ្ម័នទី៧ ក្នុងចន្លោះរវាងឆ្នាំ១២១៨-១៣៣៦ មិនសូវមានព្រះកិត្តិនាមល្បីល្បាញ ដូចស្ដេចមុនៗទេ។ ចក្រភពអង្គរ បានចាប់ផ្ដើមធ្លាក់ចុះ។**

នៅក្នុងរយៈពេលនេះ មហាក្សត្រ៥អង្គបានសោយរាជ្យជាបន្តបន្ទាប់ : ឥន្ទ្រវរ្ម័នទី២ (ប្រហែល១២១៨-១២៤៣) ជ័យវរ្ម័នទី៨ (១២៤៣-១២៩៥) ឥន្ទ្រវរ្ម័នទី៣ រឺស្រីន្ទ្រវរ្ម័ន (១២៩៥-១៣០៧) ស្រីន្ទ្រជ័យវរ្ម័ន (១៣០៧-១៣២៧) និងជ័យវរ្ម័នទី៩ (១៣២៧-១៣៣៦)។ ព្រះរាជាទាំងនេះទតឃើញថា មហាអំណាចខ្មែរបានធ្លាក់ចុះហើយ។ ទោះបីយ៉ាងនេះក៏ដោយ ក៏ព្រះរាជាណាចក្រនៅតែមានសម្បត្តិមហាសាលនិងមានអរិយធម៌ខ្ពង់ខ្ពស់លើតឆាយនៅឡើយ។ ព្រះរាជានិងបរិវាររស់នៅក្នុងភាពសំបូរសប្បាយ។ ប៉ុន្តែជារឿយៗ ភាពរុងរឿងនិងការល្បីល្បាញពីអតីតកាលច្រើនធ្វើអោយគេភ្លេចគិតដល់គ្រោះថ្នាក់នាពេលបច្ចុប្បន្ន។ មួយរយៈពេលមកហើយ ដែលគេប្រហែលជាមិនសូវបានយកចិត្តទុកដាក់លើវិស័យកសិកម្មប៉ុន្មានទេ ព្រោះតែជាប់ដៃកសាងប្រាសាទធំៗកាន់តែច្រើនឡើងៗ តាមការឈ្វេងយល់របស់ព្រះរាជា។ ប្រទេសជាតិចាប់ផ្ដើមធ្លាក់ចុះក្រ និងខ្សោយកំលាំង។ លើសពីនេះ ការគ្មានច្បាប់ទំលាប់ច្បាស់លាស់ក្នុងការស្នងរាជ្យបន្ត ធ្វើអោយកើតទំនាស់ក្នុងរាជវង្ស។ ឯទំនាស់រវាងអ្នកកាន់សាសនាព្រាហ្មណ៍និងអ្នកកាន់សាសនាព្រះពុទ្ធផ្ទុះឡើងជាហូរហែ។ សត្រូវខាងក្រៅបានឆ្លៀតឱកាសចូលឈ្លានពាន ក្នុងពេលដែលប្រទេសខ្មែរកំពុងតែចុះខ្សោយ និងបែកបាក់គ្នា។

### សំណាញ់ដឹងទេថា

នៅឆ្នាំ១២៩៦ គណៈបេសកកម្មចិនមួយ បានមកដល់ប្រទេសខ្មែរដើម្បីចរចាពីបញ្ហាសួយសារអាករ។ លោក ជីវតាក្វាន់ បានធ្វើដំណើរមកជាមួយដែរ។ ពេលត្រលប់ទៅវិញ គាត់បានសរសេរពីទឹកដីនិងប្រពៃណីខ្មែរ។

### សាកល្បងរកចំលើយ

បន្តពីព្រះបាទជ័យវរ្ម័នទី៧ តើស្ដេចអង្គណាសោយរាជ្យបានយូរជាងគេ :

- ឥន្ទ្រវរ្ម័នទី២ ?
- ជ័យវរ្ម័នទី៨ ?
- ឥន្ទ្រវរ្ម័នទី៣ ?

ចំលើយ : ទំព័រ៤៤



# ព្រះរាជាណាចក្រជិតខាង

**ក្រោយរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ចក្រភពអង្គរចាប់បាត់បង់អំនាចទៅលើប្រទេសជិតខាងនិងបាត់បង់ទឹកដី។ ហេតុការណ៍មួយសំខាន់ទៀត គឺការវាយលុកពីកងទ័ពម៉ុងកូល។**

នៅខាងកើត ពួកចាមដែលធ្លាប់ចំនុះខ្មែរតាំងពីឆ្នាំ១២០៣មក បានរើបំរះដណ្ដើមយកឯករាជ្យរបស់គេវិញនៅឆ្នាំ១២២០។ នៅខាងលិច ពួកសៀមដែលបានចូលមករស់នៅលាយឡំជាមួយខ្មែរជាយូរមកហើយ បានទទួលពួកសៀមចំនួលថ្មីដែលរត់គេចពីពួកម៉ុងកូល។ ពួកសៀមទាំងនោះបានងើបឡើងប្រឆាំងខ្មែរ ហើយបង្កើតរាជាណាចក្រសៀមនៅសុខោទ័យនៅស.វ.ទី១៣។ រដ្ឋដ៏ក្មេងអោយខ្លាចរអែងនេះចាប់ធ្វើចំបាំងប្រឆាំងកម្ពុជានិងរាតត្បាតទីជនបទខ្មែរ សំដៅមកក្រុងអង្គរ។ ឯពួកម៉ុងកូល បន្ទាប់ពីវាយយកបាននិងកាន់កាប់ប្រទេសចិន បានធ្វើការឈ្លានពានមកលើអាស៊ីភាគអាគ្នេយ៍ទាំងមូល។ ពួកម៉ុងកូលក៏បានចូលមកវាយប្រទេសខ្មែរដែរ តែបង្កអោយមានការខូចខាតតិចតួចទេ។ នៅពាក់កណ្ដាលស.វ.ទី១៤ នៅទិសខាងជើងក្សត្រឡាវនាមផាងុមបានបង្កើតរាជាណាចក្រមួយនៅលើអាណាខេត្តខ្មែរ។ រាជាណាចក្រនោះមានឈ្មោះថា «ឡានសាង» (រាជាណាចក្រដំរីមួយលាន គឺប្រទេសឡាវបច្ចុប្បន្ន) ដែលមានរាជធានីនៅល្វងព្រះបាង។ ក្រោយមកទៀតប្រទេសដៃវៀត ដែលបានលេបយកប្រទេសចាម្ប៉ា ក៏ក្លាយជាសត្រូវធំរបស់ខ្មែរ។

### សំណាញ់ដឹងទេថា

នៅឆ្នាំ១២៨៣ ពេលកងទ័ពម៉ុងកូលវាយលុកចូលកម្ពុជា ខ្មែរចាប់បានមេទ័ពម៉ុងកូល ២នាក់ ហើយឃុំឃាំងទុកជាឈ្លើយ។ ប៉ុន្តែដោយការប្រុងប្រយ័ត្ន ព្រះមហាក្សត្រខ្មែរ (ព្រះបាទជ័យវរ្ម័នទី៨) បានលើកសួយសារអាករទៅថ្វាយស្ដេចម៉ុងកូលវិញដែរ។



ទាហានម៉ុងកូល

# ប្រតិកម្មសាសនា

## នៅ ស.វ.ទី១៣



រូបព្រះពុទ្ធ ដែលត្រូវគេគោសលុប (ប្រាសាទព្រះខាន់)។

នៅសម័យអង្គរ ព្រះរាជាខ្លះកាន់សាសនាព្រាហ្មណ៍ ខ្លះទៀតកាន់ពុទ្ធសាសនា។ ការផ្លាស់ប្តូរសាសនា ត្រលប់ចុះឡើងៗ តាមចន្ទលចិត្តរបស់ព្រះរាជា បានបង្កអោយពួកព្រាហ្មណ៍និយមនិងពួកពុទ្ធនិយមមានប្រតិកម្មប្រឆាំងគ្នា ដែលជាកត្តាមួយធ្វើអោយសង្គមខ្មែរបែកបាក់គ្នា និងចុះខ្សោយ។

ព្រះបាទជ័យវរ្ម័នទី៧ជាមហាក្សត្រមួយព្រះអង្គ ដែលមានព្រះទ័យសន្តោសប្រណី។ ព្រះអង្គបានលើកតំកើងពុទ្ធសាសនាមហាយាន។ ប៉ុន្តែក្រោយមក ពុទ្ធសាសនាហីនយានរឺពុទ្ធសាសនាថេរវាទ ដែលប្រើភាសាបាលី បានចូលមកជំនួសវិញ។ ពុទ្ធសាសនាហីនយាននេះមិនអាចនៅលាយគ្នាជាមួយព្រាហ្មណ៍សាសនា រឺជាមួយលទ្ធិទេវរាជឡើយ។ ដោយហេតុនេះ ពួកព្រាហ្មណ៍ពុំសូវបានទទួលការគោរពដូចមុនទៀតឡើយ។ ពួកព្រាហ្មណ៍មិនសប្បាយចិត្តទេ។ ដោយបានទទួលការអនុគ្រោះសាជាថ្មីក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៨ ពួកព្រាហ្មណ៍ក៏នាំប្រជារាស្រ្ត ដែលកាន់សាសនាព្រាហ្មណ៍ អោយក្រោកបះបោរឡើង : គេបំផ្លិចបំផ្លាញវត្តអារាមខាងពុទ្ធសាសនា ផ្តួលរំលំ និងវាយបំបាក់បំបែកបដិមាព្រះពុទ្ធ។ ឯរូបចំលាក់ព្រះពុទ្ធនៅលើជញ្ជាំងនិងសសរបានត្រូវគេគោសលុប រួចកសាងលិង្គព្រះឥសូរឺរូបតាបសតាំងសីលជំនួសវិញ។ ទង្វើរបស់ពួកព្រាហ្មណ៍បែបនេះបណ្តាលអោយអ្នកពុទ្ធនិយមធ្វើចលនាប្រឆាំងតបតវិញ ដែលជាហេតុធ្វើអោយកើតមានការបែកបាក់រវាងខ្មែរនិងខ្មែរគ្នាឯង។ នេះជាឱកាសអោយសៀមពង្រីងអំនាចរបស់គេកាន់តែរឹងមាំឡើងៗ ហើយត្រៀមវាយលុកចូលក្រុងអង្គរ។



ពុទ្ធបរិស័ទថ្វាយបង្គំព្រះ។



# ពុទ្ធសាសនាមហាយាន និងហីនយាន

ក្រោយពីព្រះពុទ្ធអង្គចូលបរិនិព្វានទៅ ពុទ្ធសាសនាត្រូវបែកជានិកាយពីរ គឺមហាយាននិងហីនយាន។ នៅប្រទេសខ្មែរ គេឃើញមាននិកាយទាំងពីរ តែក្រោយមកនិកាយហីនយានក្លាយជាសាសនាផ្លូវការ។



១ ២

ប្រជ្ញាបារមីតា (១) និងលោកេស្វរៈ (២) ដែលជាពោធិសត្វក្នុងមហាយាន

និកាយមហាយានជាយានធំ (តាមន័យប្រៀបធៀប) រឺមានធម៌ជាយានដ៏ធំអាចនាំសត្វលោកបានច្រើនទៅកាន់គោលដៅត្រឹមពោធិសត្វ ដែលមិនចូលនិព្វានទេ តែនៅជួយប្រោសសត្វលោក។ និកាយនេះមានវិន័យធូរស្រាល ហើយគោរពធម៌វិន័យតាមគ្រូអាចារ្យរបស់ខ្លួន។ និកាយមហាយានអាចនៅលាយគ្នាជាមួយព្រាហ្មណ៍សាសនា។ ម្ល៉ោះហើយ គេអាចគោរពលទ្ធិទេវរាជនិងសាងប្រាសាទធំៗល្អឆើតឆាយ ដែលគេបិទមិនអោយប្រជារាស្រ្តចូល។ ព្រះបាទសូរ្យវរ្ម័នទី១ និងជ័យវរ្ម័នទី៧ព្រមទាំងអគ្គមហេសីកាន់និកាយនេះ។

ឯនិកាយហីនយាន រឺថេរវាទ ជាយានតូច រឺមានធម៌ជាយានដ៏តូចអាចនាំពុទ្ធសាសនិកបានចំនួនតិចទៅកាន់និព្វាន។ និកាយហីនយានមានវិន័យតឹងរ៉ឹងម៉ត់ចត់ និងគោរពបូជាព្រះពុទ្ធ ដែលបានត្រាស់ដឹង និងចូលនិព្វានទៅហើយ។ ហីនយានពុំតំរូវអោយមានប្រាសាទធ្វើអំពីថ្មទេ មានតែវត្តអារាមសង់អំពីឈើបើកចំហសំរាប់មនុស្សគ្រប់ៗគ្នា ទាំងប្រជារាស្រ្តតូចតាច ទាំងអ្នកធំ។ ប្រទេសកម្ពុជាកាន់ពុទ្ធសាសនាហីនយានជាផ្លូវការតាំងពីរាជ្យព្រះបាទត្រសក់ផ្អែមរហូតមកដល់សព្វថ្ងៃ។





ពុទ្ធសាសនានៅទ្វីបអាស៊ី



ព្រះពុទ្ធរូបសម័យក្រោយអង្គរ

### សំណាញ់ដឹងទេថា

សព្វថ្ងៃនេះ នៅលើពិភពលោកទាំងមូល មានអ្នកកាន់ពុទ្ធ-សាសនាប្រមាណជាង ៣៥២ លាននាក់ ត្រូវជា៥.៦% នៃប្រជាជនពិភពលោក។

# ត្រសក់ផ្អែម-ស្តេចបញ្ចប់លទ្ធិទេវរាជ

១៣៣៦-១៣៤០



សាស្ត្រាស្លឹករឹត

**ចលនាប្រឆាំងគ្នារវាងអ្នកព្រាហ្មណ៍និយម និងអ្នកពុទ្ធនិយម បានត្រូវបញ្ចប់នៅរវាងឆ្នាំ១៣៣៦។ នៅឆ្នាំនោះ រដ្ឋបុរសម្នាក់ឈ្មោះត្រសក់ផ្អែមបានឡើងសោយរាជ្យ ដោយមានព្រះនាមថាព្រះបាទត្រសក់ផ្អែម។**

អ្នកប្រវត្តិសាស្ត្រសន្និដ្ឋានថា នាយត្រសក់ផ្អែមជាអ្នកដឹកនាំបដិវត្តន៍ ដែលបានវាយរំលំផ្តួលលទ្ធិទេវរាជ និងបានធ្វើឃាតព្រះរាជាមុន។ ព្រះបាទត្រសក់ផ្អែមបានបង្កើតរាជវង្សថ្មី និងបានធ្វើអោយសង្គមខ្មែរផ្លាស់ប្តូរច្រើន។ ពួកព្រាហ្មណ៍បាត់បង់ឥទ្ធិពលរហូតមក។ ពុទ្ធសាសនាហីនយាន ដែលប្រជារាស្ត្រខ្មែរនិយមចូលចិត្តប្រតិបត្តិតាម ក្លាយជាសាសនាផ្លូវការ។ ការអប់រំស្ថិតនៅក្រោមកិច្ចគ្រប់គ្រងរបស់ភិក្ខុសង្ឃហីនយាន។ ពុំមានសិលាចារឹកជាភាសាសំស្ក្រឹតទៀតឡើយ។ ស្តេចសោយរាជ្យលែងប្រើព្រះនាម «វរ្ម័ន» ទៀតហើយ។ វត្តអារាមសំរាប់គោរពបូជាព្រះពុទ្ធសាសនាកើតមានឡើងព្រោងព្រាត ពាសពេញផ្ទៃប្រទេស។ ព្រះបាទត្រសក់ផ្អែមគ្រប់គ្រងរដ្ឋតាមរបៀបថ្មីសំរបសំរួលទៅតាមទស្សនវិជ្ជារបស់ពុទ្ធសាសនាហីនយាន។

### សំណាញ់ដឹងទេថា

ស្តេចចុងក្រោយបង្អស់ ដែលមានឈ្មោះចារក្នុងសិលាចារឹក គឺព្រះបាទជ័យវរ្ម័នទី៩។ បន្តមកទៀត ប្រវត្តិសាស្ត្រខ្មែរត្រូវពឹងផ្អែកលើរាជពង្សាវតារ អត្ថបទបុរាណចារលើសាស្ត្រាស្លឹករឹតនិងការទន្ទេញចាំមាត់។

ព្រះបាទត្រសក់ផ្អែមបានរៀបអភិសេកជាមួយបុត្រីស្តេចមុន។ ព្រះអង្គមានបុត្រាពីរអង្គ ដែលបានឡើងសោយរាជ្យជាបន្តបន្ទាប់។ ទោះជាសម័យនោះកម្ពុជាមិនខ្លាំងពូកែដូចកាលពីសម័យមហាក្សត្រមុនៗក៏ដោយ ក៏មហានគរនៅជារាជាណាចក្រមួយរីកចំរើនដែរ។ ប៉ុន្តែចៅរបស់ព្រះអង្គព្រះនាមលំពង្សរាជា បានជួបគ្រោះកំនាចពីសំនាក់ពួកសៀម។

### នាយត្រសក់ផ្អែមតាមរឿងនិទាន

ពាក់ព័ន្ធនឹងព្រះបាទត្រសក់ផ្អែម មានរឿងតំនាលខុសៗគ្នា ប៉ុន្តែរឿងទាំងនោះមានចំនុចស្របគ្នាដូចខាងក្រោម។ នាយត្រសក់ផ្អែមជាអ្នកចំការដ៏ប៉ិនប្រសប់ម្នាក់។ គាត់ដាំត្រសក់មានរសជាតិផ្អែមឆ្ងាញ់ពិសាជាងត្រសក់ទាំងឡាយ។ គាត់បេះផ្លែត្រសក់យកទៅថ្វាយព្រះរាជា។ ព្រះអង្គសព្វព្រះទ័យណាស់។ ទ្រង់ត្រាស់បង្គាប់អោយគាត់រក្សាទុកផ្លែត្រសក់ទាំងអស់សំរាប់ទ្រង់ ហើយប្រទានលំពែងមួយដល់គាត់សំរាប់ការពារចំការត្រសក់នោះ។ នៅយប់មួយព្រះរាជាបានលបចូលទៅក្នុងចំការរបស់គាត់។ ដោយអចេតនា ព្រោះស្មានថាជាចោរ នាយត្រសក់ផ្អែមបានពួយលំពែងទៅលើព្រះអង្គ ធ្វើអោយទ្រង់សុគតទៅ។ នាម៉ឺនសព្វមុខមន្ត្រីត្រូវរើសស្តេចថ្មី។ ពួកគេក៏ព្រមព្រៀងគ្នាអញ្ជើញនាយត្រសក់ផ្អែមអោយឡើងសោយរាជ្យជាស្តេចផែនដីទៅ។



ព្រះរាជាប្រទានលំពែងអោយនាយត្រសក់ផ្អែម សំរាប់ការពារចំការត្រសក់។

### ក្រោយពេលឡើងសោយរាជ្យ

ព្រះបាទត្រសក់ផ្អែមបានយាងទៅគង់នៅបន្ទាយសំរែ ចំងាយប្រមាណ១៥ គម ពីក្រុងអង្គរ មិនឆ្ងាយប៉ុន្មានពីប្រាសាទបន្ទាយស្រី។

# ទំនាក់ទំនងជាមួយចិន និងសៀម
## នៅ ស.វ.ទី១៤

**ជីវតាក្វាន់ នាចុង ស.វ.ទី១៣ សរសេរថា ៖**

« ពួកជនជាតិចិន... កាលមកដល់ស្រុកនេះ (ស្រុកខ្មែរ) ក៏ពេញចិត្តគេខ្លាំងណាស់ ព្រោះស្រុកនេះមិនពាច់ប្រើសំលៀកបំពាក់ច្រើន ហើយអង្ករក៏ស្រួលរក ប្រពន្ធក៏ស្រួលរក ឯផ្ទះក៏ងាយធ្វើ គ្រឿងប្រើប្រាស់ងាយរក ការលក់ដូរក៏ធូរងាយ។ »



កងទ័ពចិន (ចំលាក់នៅថែវប្រាសាទបាយ័ន)

**នៅសតវត្សទី១៤ ទន្ទឹមនឹងការបន្តទំនាក់ទំនងធម្មតាជាមួយចិន ខ្មែរត្រូវធ្វើសឹកសង្គ្រាមជាច្រើនលើកតទល់នឹងសៀម ដែលបានលើកកងទ័ពចូលមកឈ្លានពានទឹកដីអង្គរ ។**

### ▸ ទំនាក់ទំនងជាមួយចិន

នៅពេញសតវត្សទី១៤ ព្រះមហាក្សត្រខ្មែរទាំងឡាយខិតខំពង្រឹងអំនាចរាជាណាចក្រដោយបន្តបញ្ជូនរាជទូតទៅប្រទេសចិន។ ឯប្រទេសនេះក៏បានបញ្ជូនបេសកជនខ្លួនមកក្រុងអង្គរវិញ ជាហូរហែដែរ ដើម្បីប្រមូលសួយ។ ប្រទេសចិនយល់ថា វិធីនេះអាចជួយពង្រឹងឥទ្ធិពលចិនទៅលើប្រទេសជុំវិញខ្លួនគេ។ ឯមហាក្សត្រខ្មែរក៏គិតថាបានចំនេញដែរ ដោយមានប្រទេសធំបំផុតក្នុងតំបន់ទទួលស្គាល់។ ឋានន្តរជាកិត្តិយស ដែលស្តេចស្រុកចិនប្រគល់អោយ មានតំលៃធំធេងណាស់។ ដូចនេះហើយទើបគេតែងតែឃើញមានគណៈប្រតិភូចិនមកចូលរួមក្នុងពិធីបូជាសពព្រះរាជាខ្មែរនិងក្នុងពិធីអភិសេកឡើងគ្រងរាជ្យសម្បត្តិរបស់ស្តេចថ្មី។ កាលប្បវត្តិចិននិយាយពីរឿងនេះជាញឹកញាប់។ លើសពីនេះ ការដោះដូរផ្នែកពាណិជ្ជកម្មរវាងប្រទេសទាំងពីររីកចំរើនខ្លាំងឡើងៗ។ កម្ពុជាបញ្ជូនសត្វដ៏វិសេសដែលគេបានផ្សាំងរួច ភ្លុក ឈើមានតំលៃ ទឹកអប់ ស្លាបក្ងោក... ទៅអោយប្រទេសចិន ហើយទទួលមកវិញនូវសំពត់ប៉ាក់ ចានក្បានល្អៗ ឆ្នាំងដែក ថូផ្កា ក្រដាសសរសេ-ល-។ ទន្ទឹមគ្នានេះ ជំនួញតាមសមុទ្រជាមួយឥណ្ឌាក៏នៅមានសកម្មភាពខ្លាំងក្លានៅឡើយ។

### ▸ ទំនាក់ទំនងជាមួយសៀម

បន្ទាប់ពីបានចុះពីខាងជើងមកតាំងរាជធានីនៅអយុធ្យា សៀមបានលើកទ័ពចូលមកវាយខ្មែរជាបន្តបន្ទាប់។ នៅឆ្នាំ១៣៥២ ស្តេចសៀមនាមរាមាធិបតីទី១បានលើកទ័ពចូលទន្ទ្រានទឹកដីខ្មែរ ហើយចូលមកហ៊ុមព័ទ្ធរាជធានីអង្គរ។ ព្រះរាជាខ្មែរនាមលំពង្សរាជា ទ្រង់ប្រឈួនហើយសុគតទៅ។ ទ័ពខ្មែរទន់ដៃ ក៏វាយរំដោះគ្នីគ្នាទៅរៀបចំការតស៊ូ។ នៅពេលនោះ សៀមចូលរាតត្បាតក្រុងអង្គរ កាប់សំលាប់ ឆក់ប្លន់ទ្រព្យសម្បត្តិ និងកៀរខ្មែរយកទៅជាឈ្លើយ។ ស្តេចសៀមលើកបុត្រាខ្លួនអោយសោយរាជ្យនៅអង្គរ។ ប៉ុន្តែសៀមមិនអាចនៅបានយូរឡើយ។ ព្រះបាទស្រីសុរិយោវង្សលើកទ័ពមកវាយរំដោះយកអង្គរបានវិញ ហើយឡើងគ្រងរាជ្យ។ ទ្រង់បានលើកទ័ពទៅសំអាតសត្រូវពីអាណាខេត្តខ្មែរ ហើយរក្សាព្រំដែនត្រឹមខេត្តចន្ទបុរី បស្ចិមនិងនគររាជសីមា។ កម្ពុជាបានសុខសន្តិភាពមួយរយៈកាល។ ប្រហែលនៅឆ្នាំ១៣៩៤ ទើបសៀមសាកល្បងវាយយកក្រុងអង្គរជាលើកទី២ រួចកៀរខ្មែរជាច្រើនម៉ឺននាក់យកទៅជាឈ្លើយ។ ក្រោយមករវាងឆ្នាំ១៤២០ សង្គ្រាមខ្មែរ-សៀមដ៏ធំមួយបានផ្ទុះឡើងទៀត។ ពេលនោះ ក្សត្រខ្មែរនាមពញាយ៉ាតបានវាយទំលាយការឡោមព័ទ្ធ គេចខ្លួនទៅប្រមូលកំលាំងតស៊ូ។ សៀមចូលលុកលុយក្រុងអង្គរ លើកបុត្រាស្តេចសៀមអោយសោយរាជ្យ ដឹកជញ្ជូនទ្រព្យសម្បត្តិ និងកៀរខ្មែររាប់ពាន់គ្រួសារយកទៅស្រុកគេ។ លុះក្រោយមក ទើបក្សត្រពញាយ៉ាតវិលមកកំទេចទ័ពសៀមវិនាសអស់ពីអង្គរ។ ទ្រង់បានទទួលអភិសេកឡើងគ្រងរាជ្យដោយសុខសាន្ត។ ប៉ុន្តែអំនាចចក្រភពអង្គរបានចុះខ្សោយណាស់ទៅហើយ។

នៅឆ្នាំ ១៣៦៨ នៅឯស្រុកចិន រាជវង្សមិញបានឡើងសោយរាជ្យបន្តពីរាជវង្សយ័ន ដែលជារាជវង្សម៉ុងហ្គូល។

### សំណាញ់និងមេថា

នៅពេលឈ្នះសង្គ្រាមឆ្នាំ១៣៥២ កងទ័ពសៀមចាប់អ្នកទីក្រុងរាប់ម៉ឺននាក់ ព្រមទាំងសមាជិកក្រុមល្ខោនព្រះរាជទ្រព្យទាំងអស់នាំយកជាឈ្លើយទៅក្រុងអយុធ្យា។



អង្គរធំ ត្រូវសៀមដុតបំផ្លាញ ប្រជារាស្ត្រខ្មែរត្រូវសៀមកៀរយកទៅជាឈ្លើយ។

# អរិយធម៌អង្គរ

នៅសម័យអង្គរ អរិយធម៌ខ្មែរបានឡើងរុងរឿងខ្ពង់ខ្ពស់ដល់កំរិតកំពូល។ ចក្រភពអង្គរមានឈ្មោះជាមហាអំនាចនៅអាស៊ីភាគអាគ្នេយ៍។

**សវនាការរបស់ព្រះរាជា**

« ក្នុងមួយថ្ងៃ ព្រះរាជាទទួលសវនាការ២លើក។ មន្ត្រី រាស្ត្រ ដែលចង់ចូលគាល់ ត្រូវចូលទៅអង្គុយបត់ជើងផ្ទាល់ដីរង់ចាំជាមុន។ មួយសន្ទុះក្រោយមក គេលឺសំលេងតន្ត្រីរងំពីខាងក្នុង។ អ្នកនៅខាងក្រៅផ្លុំស័ង្ខតបទៅវិញ...។ បន្តិចក្រោយមក គេឃើញស្រីស្នំ ២នាក់រូតវាំងននឡើង ក៏លេចឃើញស្ដេចគង់ឈរកាន់ព្រះខាន់ នៅក្នុងស៊ុមមាសជាទីព្រះទែនគង់ប្រថាប់... »

(ជីវតាក្វាន់)

## ▶ តើព្រះមហាក្សត្រសម័យអង្គររស់នៅបែបណា ?

ព្រះរាជាជាម្ចាស់ផែនដី មានអំនាចទូលំទូលាយណាស់ ព្រោះអំនាចរបស់ទ្រង់មានប្រភពចេញមកពីអាទិទេព។ ព្រះរាជាជាអ្នកជ្រើសរើសមន្ត្រីរាជការជាន់ខ្ពស់ ជាមេបញ្ជាការកងទ័ព ជាអ្នកធ្វើច្បាប់ ជាមេសាសនា ជាអ្នកកាត់ក្ដី ជាអ្នកគ្រប់គ្រងនយោបាយ និងសំរេចរាល់កិច្ចការឯទៀតៗ។ ដីក្នុងមហានគរជារបស់ព្រះអង្គផ្ទាល់ ប៉ុន្តែទ្រង់ប្រគល់អោយប្រជារាស្ត្រប្រើប្រាស់ ដោយឥតយកថ្លៃ។ ភារកិច្ចរបស់ព្រះមហាក្សត្រធំទូលំទូលាយណាស់ ដូចបុព្វសិទ្ធិរបស់ព្រះអង្គដែរ។ ទ្រង់ជាអ្នកការពារប្រជារាស្ត្រ និងជាអ្នកធ្វើអោយប្រជារាស្ត្របានសុខសន្តិភាពសំបូរសប្បាយរុងរឿងទៀតផង។ ព្រះអង្គគង់នៅក្នុងវាំងសង់ពីឈើតាមពិធីការមួយដ៏សែនប្រិតប្រៀង។ សវនាការនិងការយាងចេញរបស់ព្រះអង្គតែងប្រព្រឹត្តទៅតាមក្បួនយ៉ាងច្បាស់លាស់។ ព្រះអង្គចូលរួមក្នុងពិធីបុណ្យទានផ្សេងៗ។ ព្រះរាជាគ្រប់គ្រងប្រទេសតាមរយៈរដ្ឋបាល ដែលមានការរៀបចំយ៉ាងល្អិតល្អន់ មានតាំងពីរដ្ឋមន្ត្រី មេទ័ព ទីប្រឹក្សា អធិការ ចៅហ្វាយខេត្ត រហូតដល់មេស្រុក មេភូមិ មេឃ្លាំង មេខ្លង(?)-ល-។



ការយាងចេញរបស់ព្រះរាជា (ថែវប្រាសាទអង្គរវត្ត)











ជីវភាពប្រចាំថ្ងៃរបស់ប្រជាជន (ថែវប្រាសាទបាយ័ន)

## ▶ សង្គមនិងជីវិតប្រចាំថ្ងៃ នៅសម័យអង្គរ

ពួកព្រាហ្មណ៍បាននាំមកអោយប្រជាជនខ្មែរនូវក្បួនច្បាប់ផ្សេងៗ ក្នុងនោះមានការបែងចែកសង្គមជាវណ្ណៈផងដែរ ៖ ពួកក្សត្រនិងព្រាហ្មណ៍ជាបញ្ញវន្ត ពួកអភិជនជាអ្នកចបាំង ឯឈ្មួញព្រមទាំងកសិករនិងសិប្បករជាពលករ។ គេក៏ឃើញមានពលរដ្ឋមួយប្រភេទទៀតដែរ ហៅថា «ពលព្រះ» ដែលនៅថែទាំបោសសំអាតវត្តអារាមនិងប្រាសាទ។ ប៉ុន្តែគេមិនបានគោរពការបែងចែកខាងលើនេះ ដាច់ណាត់ទេ។ នៅក្នុងភូមិ គេតែងជួបជុំគ្នា ដូចជាគ្រួសារតែមួយ។ ទាំងអស់គ្នាចូលរួមក្នុងពិធីបុណ្យធំៗរបស់ជាតិ ៖ ពិធីបុណ្យចូលឆ្នាំ ពិធីដារលាន ពិធីច្រត់ព្រះនង្គ័ល បុណ្យអុំទូក...។ នៅគ្រប់ទីកន្លែង ជីវិតប្រចាំថ្ងៃតែងប្រព្រឹត្តទៅដោយមានការចូលរួមពីកសិករ អ្នកលក់ដូរ ពួកអភិជន និងរាស្ត្រតូចតាច។ ជនជាតិចិនជាភ្ញៀវម្នាក់បានរៀបរាប់ពីដំណើរជីវិតនេះ ហើយរូបចំលាក់នៅតាមប្រាសាទក៏បានបង្ហាញរឿងនេះ យ៉ាងល្អិតដែរ។ នៅក្នុងសង្គមនោះ ស្ត្រីមានតួនាទីសំខាន់ ៖ មានស្ត្រីជាអ្នកជំនួញ ជាហោរា ជាអ្នករាជការ ជាសាស្ត្រាចារ្យ...។

**ឈ្មួញ**

« ពួកគេពុំមានគ្រែ រឺផ្ទះសំរាប់ដាក់អីវ៉ាន់ទេ គេច្រើនតែក្រាលវត្ថុហាក់ដូចជាកន្ទេលផ្ទាល់ទៅនឹងដីតំរៀបគ្នា...។ ជំនួញតូចតាច គឺគេជួញស្រូវអង្ករ និងរបស់ផ្ញើមកពីស្រុកចិន។ បន្ទាប់មក មានលក់ដូរសំពត់ផ្សេងៗ។ ជំនួញធំគឺគេជួញមាសប្រាក់។ »

**ព្រាហ្មណ៍ និងសង្ឃ**

« ពួកព្រាហ្មណ៍ស្លៀកពាក់ដូចជនធម្មតាដែរ តែប្លែកត្រង់ពាក់អំបោះសវេញមួយខ្សែនៅក។ ឯលោកសង្ឃវិញកោរព្រះកេស គ្រងចីវរពណ៌លឿង បញ្ចេញស្មាខាងស្ដាំ ហើយនិមន្តដោយជើងទទេ។ លោកសង្ឃឆាន់មួយពេលក្នុងមួយថ្ងៃ ហើយសូត្រធម៌ ដែលមានសរសេរលើសាស្ត្រាស្លឹករឹត។ »

(ជីវតាក្វាន់)





ទ័ពដំរី ទ័ពសេះ ទ័ពថ្មើរជើង និង ពលដឹកជញ្ជូនស្បៀង (ប្រាសាទបាយ័ន)



កងទ័ពជើងទឹក (ប្រាសាទបាយ័ន)

### ▶ ទ្រព្យសម្បត្តិច្រើនស្តុកស្តម្ភ និងកងទ័ពខ្លាំងពូកែ

ប្រទេសកម្ពុជាល្បើរន្ទឺទៅឆ្ងាយថា មានទ្រព្យសម្បត្តិច្រើន។ ការសរសើរបស់ជៀវចិន និងព្រះរាជអំណោយជាទ្រព្យសម្បត្តិជាច្រើនដល់វត្តអារាមជាសាក្សីស្រាប់។ ភាពសំបូរនេះបានមកពីធនធានធម្មជាតិ និងពីនយោបាយសេដ្ឋកិច្ចរបស់ព្រះមហាក្សត្រខ្មែរ។ បច្ចេកទេសខាងការស្តុកទឹកក្នុងបារាយណ៍ធំៗ ខាងការបង្ហូរទឹកយកទៅស្រោចស្រពស្រែ ដោយពុំពឹងផ្អែកតែទៅលើទឹកភ្លៀង និងការចេះធ្វើស្រែយ៉ាងប៉ិនប្រសប់ អាចអោយគេធ្វើស្រែបានច្រើនដងក្នុងមួយឆ្នាំៗ។ នៅសម័យនោះ កម្ពុជាជាតំបន់កសិកម្មសំបូរបំផុតនៅទ្វីបអាស៊ី។ ម្យ៉ាងទៀតកម្ពុជាក៏ស្ថិតនៅលើផ្លូវជំនួញធំៗ ដែលនាំឆ្ពោះទៅតំបន់ផ្សេងៗដូចជាប្រទេសចិន ជប៉ុន ឲ្រកម៉ាឡាកា ប្រទេសឥណ្ឌា និងបស្ចិមប្រទេស។ ដើម្បីការពារទ្រព្យសម្បត្តិនិងភាពរុងរឿងនេះ ព្រះមហាក្សត្រអង្គរត្រូវមានអំណាចទូលំទូលាយ មានរដ្ឋបាលរឹងមាំ និងមានកងទ័ពខ្លាំងពូកែ។ កងទ័ពចេញទៅច្បាំងក្រោមការដឹកនាំផ្ទាល់របស់ព្រះរាជា។ ពលទាហានមានជំនឿទៅលើព្រះអង្គ មានវិន័យល្អនិងចិត្តក្លាហានក្នុងការប្រយុទ្ធ។ តាមរូបចំលាក់នៅលើជញ្ជាំងប្រាសាទបាយ័ន ទ័ពខ្មែរយើងជំនាន់នោះមានពលថ្មើរជើង ពលសេះ ពលដំរី ពលជើងទឹក និងពលផ្គត់ផ្គង់ស្បៀង។

**ទ័ពថ្មើរជើង**

« កងទ័ពធ្វើដំណើរ ដោយលែងខ្លួនទទេឥតអាវ។ ដៃស្តាំគេកាន់លំពែង ដៃឆ្វេងកាន់ខែល គ្មានប្រើធ្នូនិងព្រួញទេ កាំភ្លើងធំ រឺអាវក្រោះ ក៏គ្មានដែរ។ »

(ជីវតាក្វាន់)



# ចំនាកចំនោលក្រុងអង្គរ

**ដោយគ្មានសង្ឃឹមនឹងស្តារក្រុងអង្គរអោយបានចំរើនល្វតលាស់ដូចដើមវិញ បន្ទាប់ពីរងការបំផ្លិចបំផ្លាញពីសំនាក់ពួកសៀម ព្រះបាទពញាយ៉ាតបានសំរេចចាកចោលអង្គរ នៅឆ្នាំ១៤៣១។**

ដោយសារសង្គ្រាមច្រើនលើកច្រើនសា ចក្រភពអង្គរត្រូវវិនាសខ្ទេចខ្ទាំ។ អាងទឹកនិងប្រព័ន្ធប្រលាយទឹកសំរាប់ស្រោចស្រពស្រែ ដែលធ្លាប់ធ្វើអោយកម្ពុជាសំបូររុងរឿង បានត្រូវខូចខាត។ កម្ពុជាបាត់បង់ទាំងមនុស្សទាំងទ្រព្យសម្បត្តិអស់ជាច្រើន។ ប្រជារាស្ត្រមួយភាគត្រូវស្លាប់ដោយសង្គ្រាម ហើយមួយភាគទៀតបានត្រូវសៀមកៀរយកទៅ។ នៅតំបន់អង្គរ ចំនួនប្រជាជនថយចុះច្រើនណាស់។ ស្មៅព្រៃដុះលូតលាស់វាតទីទៅលើដីស្រែបន្តិចម្តងៗ ព្រោះកសិករមានចំនួនតិច។ ជាមួយគ្នានេះ ព្រៃឈើចាប់ដុះទន្ទ្រានទៅលើប្រាង្គប្រាសាទ។ គេត្រូវស្តារអ្វីៗទាំងអស់ឡើងវិញ។ លើសពីនេះ អង្គរស្ថិតនៅជិតសត្រូវពេក (ប្រមាណ ៤០០គមពីក្រុងអយុធ្យា) ឯពលរដ្ឋអាណាខេត្តខាងលិចនៅសេសសល់តិចតួចពេក ហើយពុំអាចពឹងជាកំលាំងរាំងផ្លូវសៀមបានឡើយ។ ស្ថិតនៅចំពោះមុខស្ថានភាពថ្មីរបស់ប្រទេសជាតិបែបនេះ ព្រះបាទពញាយ៉ាតបានប្រឹក្សាសួរយោបល់ពួកមន្ត្រី ហើយសំរេចចាកចោលរាជធានីអង្គរមកតាំងរាជវាំងនៅភាគខាងត្បូងនៃប្រទេស តាមដងទន្លេមេគង្គវិញ ដំបូងនៅទួលបាសានក្នុងឆ្នាំ១៤៣១ ហើយបន្ទាប់មកទៀតនៅចតុមុខក្នុងឆ្នាំ១៤៣២។ បន្តពីនោះមក ប្រវត្តិសាស្ត្រខ្មែរបានចូលទៅក្នុងសម័យមួយថ្មីទៀត ហៅថា សម័យចតុមុខ។



ប្រាសាទតាព្រហ្មកំពុងរងការវាតត្បាតពីធម្មជាតិ។

**ក្រុងអង្គរក្រោយការបោះបង់**

ចាប់ពីឆ្នាំ១៤៣១ បន្តិចម្តងៗ ក្រុងអង្គរបានក្លាយទៅជាព្រៃបណ្តាលអោយធម្មជាតិបំផ្លិចបំផ្លាញប្រាង្គប្រាសាទបុរាណទាំងឡាយ។ តែប្រាសាទអង្គរវត្តនិងតំបន់នៅជាប់ពីខាងត្បូង ដែលមិនសូវខូចខាតដោយសង្គ្រាម នៅបន្តមានមនុស្សរស់នៅ និងធ្វើការដាំដំនាំ ព្រមទាំងទទួលព្រះរាជាម្តងម្កាល។

**សំណាញ់ដឹងទេថា**

- ▶ នៅឆ្នាំ១៤៣១ ព្រះបាទពញាយ៉ាតទ្រង់ចាកចោលក្រុងអង្គរមកតាំងរាជធានីនៅទួលបាសាន ជង្ហែជាក្បួនតាមផ្លូវទឹក។
- ▶ ក្រោយមករាជធានី បានត្រូវលើកមកតាំងនៅចតុមុខវិញ ព្រោះទួលបាសានទាបពេក ងាយលិចដោយទឹកជំនន់ទន្លេមេគង្គ។

# ពន្យល់ពាក្យ

**កុលាលភាជន៍** វត្ថុផ្សេងៗ ដែលគេធ្វើដោយដីឥដ្ឋ មានដូចជាចាន ឆ្នាំង ក្អម ផើង ពែង ថូ...។

**គូ(រឺ កសិណ)** ស្នាមភ្លោះ ដែលគេជីកព័ទ្ធជុំវិញ បន្ទាយ វាំង រឺប្រាសាទ ហើយច្រើនមានទឹកដក់នៅ។

**ជ្រែករាជ្យ** ដណ្ដើមរាជ្យ ដណ្ដើមសោយរាជ្យ។

**និកាយ** ពួក ក្រុម វង្ស។

**បេតិកភណ្ឌ** ទ្រព្យសម្បត្តិជាកេរមត៌ក ដែលគេបាន ទទួលពីបុព្វបុរស។

**បេសកកម្ម** កិច្ចការដែលមនុស្សម្នាក់ រឺមួយក្រុម បានទទួលពីថ្នាក់លើ ដើម្បីយកទៅធ្វើអោយបានសំរេច។

**មូលនិធិ** ប្រាក់សំរាប់ចំនាយធ្វើការណាមួយ។

**រជ្ជកាល** កាល រឺសម័យដែលក្សត្រមួយអង្គសោយរាជ្យ។

**រដ្ឋ** ដែនដីដែលមានប្រជាជនរស់នៅក្រោមរដ្ឋាភិបាលតែមួយ និងក្រោមច្បាប់តែមួយដូចគ្នា។

**រាជវង្ស** ក្សត្រជាបន្តបន្ទាប់គ្នា ដែលចេញមកពីគ្រួសារតែមួយ។

**វិបុលភាព** ភាពចំរើនរុងរឿង សំបូរដោយទ្រព្យ។

**វិសាលភាព** ផ្ទៃ ផ្ទៃដី។

**សក្ការៈដូនតា** ពិធីគោរពបូជាចំពោះព្រលឹងដូនតា ឪពុកម្ដាយនិងញាតិ ដែលបានស្លាប់ទៅហើយ។

**សាមន្តរដ្ឋ** រដ្ឋចំនុះគេ។

**ឯកសិទ្ធិ** សិទ្ធិ អត្ថប្រយោជន៍ពិសេស ដែលគេអោយចំពោះមនុស្សម្នាក់ រឺមួយក្រុម បន្ថែមពីលើច្បាប់ទូទៅ។

**អ្នកកាលប្បវត្តិ** អ្នកកត់ត្រាហេតុការណ៍ប្រវត្តិសាស្ត្រ តាមលំដាប់លំដោយ ពេលវេលាដែលវាបានកើតឡើង។

# ចំលើយ

- **ទំព័រ៤**

  លេខ១ : ប្រទេសចិន (១២៧៥លាននាក់)

  លេខ២ ឥណ្ឌា (១០០៨លាននាក់) ឆ្នាំ២០០០។

- **ទំព័រ៨**

  មានស្ដេចសោយរាជ្យមានងារជា «ស្ដេចភ្នំ»។

- **ទំព័រ១៤**

  សិវលិង្គតំនាងព្រះឥសូរនិងព្រះរាជា។

- **ទំព័រ១៦**

  លើកំពូលភ្នំបាខែង។

- **ទំព័រ២៣**

  ប្រាសាទអង្គរវត្តបែរមុខទៅលិច។

- **ទំព័រ៣២**

  គឺព្រះបាទជ័យវរ្ម័នទី៨ ដែលសោយរាជ្យបាន ៥២ឆ្នាំ ពីគ.ស.១២៤៣ ដល់គ.ស.១២៩៥។